មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0019**

## សម្ភាសន៍ជាមួយឈ្មោះ ម៉ុយ សុត អាយុ៩៦ឆ្នាំ ភេទប្រុស

## មុខងារខ្មែរក្រហមៈ កសិករ

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅ ភូមិគោកខ្ពស់ ឃុំរូងជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង

## សព្វថ្ងៃរស់នៅ ភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០១:៤១:៤១

## ៣៣ទំព័រ

ដានី ៖ ជំរាបសួរខ្ញុំសុំស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

សុត ៖ ខ្ញុំឈ្មោះ ម៉ុយ សុត

ដានី ៖ ចុះឈ្មោះកាលពីឪពុកម្តាយដាក់ឲ្យឈ្មោះអី?

សុត ៖ នៅតែ ម៉ុយ សុត ដដែល

ដានី ៖ ពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

សុត ៖ អាយុ៩៦ឆ្នាំ

ដានី ៖ សព្វថ្ងៃពូរស់នៅក្នុងភូមិ ឃុំ អីដែរ?

សុត ៖ ភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ដានី ៖ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

សុត ៖ ឈ្មោះ ឆួន រ៉ែត

ដានី ៖ ហើយគាត់អាយុប៉ុន្មានដែរ?

សុត ៖ ប្រពន្ធខ្ញុំអាយុ៩៧ហើយ

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ហើយ?

សុត ៖ កូន៤នាក់

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សុត ៖ ស្រី២ ប្រុស២

ដានី ៖ ពូសព្វថ្ងៃប្រកបរបរធ្វើអីដែរ?

សុត ៈ សព្វថ្ងៃធ្វើចំការ នឹងស្រែ

ដានី ៈ ពូស្រុកកំណើតពូនៅណាដែរ?

សុត ៈ ភូមិគោកខ្ពស់ ឃុំរូងជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ដានី ៈ ឪពុកម្តាយពូគាត់ឈ្មោះអីខ្លះទៅ?

សុត ៈ ឪពុកខ្ញុំ ម៉ុយ សុន ។

ដានី ៈ ចុះម្តាយ?

សុត ៈ ហេង នាង ស្លាប់អស់ហើយស្លាប់ទាំងពីរនាក់ ។

ដានី ៈ ស្លាប់ឆ្នាំណា?

សុត ៈ ម៉ែខ្ញុំស្លាប់៧៩ ឪពុកខ្ញុំស្លាប់៧៨ ។

ដានី ៈ គាត់ឈឺអីដែរ?

សុត ៈ គាត់ឈឺជំងឺសួត ម្តាយឈឺដែរគាត់ឈឺជំងឺចាស់ជរា ។

ដានី ៈ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

សុត ៈ បីនាក់ខ្ញុំ

ដានី ៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សុត ៈ ស្រីមួយ ប្រុសពីរ ស្រីបងគេ ខ្ញុំនេះប្អូនពៅ ។

ដានី ៈ ចុះពូរៀនសូត្រដល់ថ្នាក់ណា?

សុត ៈ ជំនាន់យើងកាលហ្នឹងវាទៅជនបទខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ។

ដានី ៈ ចុះចប់ពី៦៦ទៅពូទៅណាទៀត?

សុត ៈ មកធ្វើស្រែឲ្យឪពុកនៅឯភូមិគោកខ្ពស់ហ្នឹងឯង ។

ដានី ៈ ធ្វើស្រែរហូតដល់ពេលណាទៅ?

សុត ៈ ធ្វើស្រែរហូតដល់ពេលសង្គ្រាម៥ឆ្នាំ សង្គ្រាមពី៧០ដល់៧៥ ។

ដានី ៈ ចេញពីផ្ទះឆ្នាំណា?

សុត ៈ ខ្ញុំមែនទែនខ្ញុំចេញពី៧៣-៧៤ម៉ោ ដាក់៧៤ឲ្យវាច្បាស់ ។

ដានី ៈ កាលហ្នឹងមូលហេតុអីបានចេញ?

សុត ៈ ពេលនោះយើងមានសង្គ្រាម៥ឆ្នាំ ដល់ពេលអញ្ចឹងយើងចេញពីផ្ទះរបស់យើងទៅរកស៊ីនៅកន្លែងក្រុងវិញ(ស្តាប់មិនបាន)ដល់ពេល៧៥នេះគេរើសកងចល័ត ដល់រើសកងចល័តអញ្ចឹងទៅ ខ្ញុំទៅយើងក៏គេឲ្យទៅតាមផ្នែកហ្នឹងទៅ អញ្ចឹងកងរបស់យើងជាយុវជនគេអត់ឲ្យ

នៅជាមួយម៉ែឪទេ គេបំបែកហើយណាស់ គេបំបែកយើងក្នុងឆ្នាំ៧៥ហ្នឹងបញ្ចប់ សង្គ្រាម យើងមិនចូលសម័យ៣ឆ្នាំ អញ្ចឹងគេបំបែកយុវជនឲ្យនៅផ្សេង ម៉ែៗឲ្យនៅផ្សេងអត់ឲ្យ នៅជុំគ្នាទេ ដាក់តាមផ្នែកៗ យុវជនដាក់តាមយុវជនទៅ ។

ដានី ៖ បាទ!

សុត ៖ អញ្ចឹងខ្ញុំមកនៅកន្លែងព្រៃធំ ព្រៃសុទ្ធម៉ង់?

ដានី ៖ ព្រៃនៅណាទៅ?

សុត ៖ នៅភូមិយើងគេហៅថា កាតហេតុៗគុលយើងនេះគុលនៅបរិលយើងនេះនៅភូមិៗហ្នឹង គេ ហៅ ថ្នាក់ក្រលាំងព្រៃសុទ្ធម៉ង ហើយនៅត្រង់ហ្នឹងនៅជាមួយភូមិមូលដ្ឋានគេនោះណាស់ មូលដ្ឋានសុទ្ធតែដើងចាស់ពីឆ្នាំ៧០ម៉ោនៅទទួលខុសត្រូវរួមយើងនៅហ្នឹង នៅទទួលខុស ត្រូវរួមយើង នៅហ្នឹងមានបងៗយើងនិស្សិតសាស្ត្រាចារ្យ បញ្ញាជនអីដែលចេះដឹងម៉ង ឲ្យ តែអ្នកចេះដឹងចាប់ ពីកំរិតថ្នាក់ទី៧ទៅគេយកមកដាក់កន្លែងហ្នឹង រហូតដល់បាក់ឌុប បាក់ អង ។

ដានី ៖ អញ្ចឹង! ម៉េចបានគេដាក់ចឹង?

សុត ៖ អត់ដឹងដែរ! ឃើញម៉ោគេដាក់ចឹងហ្នង ខ្ញុំយកទៅពីនេះគេយកម៉ោពីក្រុងម៉ោ ដល់អញ្ចឹងនាំ គ្នាកាំបិតពូថៅម្នាក់មួយៗម៉ោគេឲ្យធ្វើពលកម្មកាប់ចំការ ភាគច្រើនទាំងអស់និស្សិត ហើយ នឹង សាស្ត្រាចារ្យដែលសុទ្ធតែអ្នកជាន់ខ្ពស់ម៉ង់ ។

ដានី ៖ ហើយយ៉ាងម៉េចទៅ?

សុត ៖ ដល់ពេលយើងនេះទៅវាមានកម្មាភិបាល គេម៉ោគ្រប់គ្រងយើង ប៉ុនទាស់កម្មាភិបាលហ្នឹង ក៏សុទ្ធតែបងប្អូនយើងដែរ ។

ដានី ៖ បងប្អូនពូដែរ?

សុត ៖ បាទ!បងប្អូនខ្ញុំដែរហ្នឹង ។

ដានី ៖ ម៉េចទៅអញ្ចឹង?

សុត ៖ បាទ!ដល់អញ្ចឹងគេឲ្យយើងគ្រប់គ្រងកម្លាំងនៅហ្នឹង សំរាប់ខ្លួនឯងនឹងនិស្សិតហើយ ខ្ញុំមាន និស្សិតអីនិស្សិតថ្នាក់ទី៧ អញ្ចឹងបងប្អូនដែលជាកម្មាភិបាលដែលមិនចេះអក្សរសោះ គេឲ្យ យើងទៅគ្រប់គ្រងកម្លាំងនៅហ្នឹងដើម្បីធ្វើការងារ ។

ដានី ៖ មានប៉ុន្មាននាក់នៅហ្នឹង?

សុត ៖ ប្រហែលជា១០០នាក់សុទ្ធតែនិស្សិតហើយនឹងសាស្ត្រាចារ្យ ហើយខ្ញុំកាលហ្នឹង មាន អាយុ២១ ពេញអាយើងទឹមរៀនចប់ដែរយើងមិនទាន់ភ្លេចនៅឡើយ ខ្ញុំចេះស្តាប់បាន បារាំង

ព្រោះនិស្សិតនៅទីនោះសុទ្ធតែអ្នកចេះបារាំងរលាយ គ្មានអ្នកចេះអង់គ្លេសទេ និស្សិតជំនាន់ហ្នឹង បើគេនិយាយម៉ោបើថាចង់គេឈឺចាប់អីមួយគេនិយាយ ម៉ោយើងស្តាប់បានស្តាប់បានបញ្ហាហ្នឹង ដល់អញ្ចឹងបង១ដែលទឹមម៉ោគាត់ឃើញខ្ញុំចេះដែរ ហើយខ្ញុំទទួលខុសត្រូវមួយផ្នែកចំពោះអ្នក ដែលមិនចេះអីសោះនៅក្នុងកងចល័តហ្នឹង ដល់អញ្ចឹងអាកម្មាភិបាលអត់ចេះអីទេ ដូចថាប្អូនខ្ញុំ ទឹមម៉ោពីអាមេរិកវាកម្មាភិបាលដូចគ្នា អាហ្នឹងវាជីដូនមួយបង្កើតរបស់ខ្ញុំអាហ្នឹងមិនចេះអក្សរសោះ នៅក្នុងព្រៃសរសេរតាមព្រៃតែអក្សរវាស្អាតណាស់ រៀនក្នុងថ្នាក់អក្សរវាស្អាតណាស់ តែសរសេរអត់ចេះនិយមន័យវាសរសេរខុស ដល់អញ្ចឹងវាខ្មាស់ដឹកនាំ ។

ដានី ៖ ដឹកនាំហ្នឹងធ្វើអីខ្លះទៅ?

សុត ៖ ដឹកនាំឲ្យកាប់ចំការ ដាំដំនាំ ដាំពោត ដាំសណ្តែក ដាំចេក ដាំអំពៅដល់អញ្ចឹងកាប់បានដី ចំនួនជាប់ប្រហែល៥០ហិចតា ហើយដូចច្នេះយើងដាំម៉ង់ ដាំតាំងពីស្រូវ យើងរៀនប៉ុណ្ណឹងយើងដឹងដែរ វាអត់មានបច្ចេកទេសអីទេពួកវាហ្នឹង តែយើងមានវិធីសាស្ត្រយើងយើងពិភាក្សាគ្នា ពីចិត្តទាំងអស់គ្នា តើធ្វើអីដើម្បីយើងបើកការពិភាក្សានេះ ដល់អញ្ចឹងពួកនោះវាយល់យើងអ្នកចេះមួយ ប៉ុនណ្ណឹងគេថាយើងអ្នកចេះដែរ ប៉ុនតែយើងមានបង្អែកខាងនោះដែរគេមិនអាច ។

ដានី ៖ ដូចថាពូមានសាច់ញាតិធ្លាប់ធ្វើ?

សុត ៖ បាទ!មានសាច់ញាតិខាងលើ ប៉ុន្តែយើងជួប់ខាងក្រោមដែរ ជៀសវាងការកាប់សម្លាប់ យើងយើងស្អប់បំផុតអំពើកាប់សម្លាប់ ដល់អញ្ចឹងអ្នកដែល១០០នាក់ហ្នឹងសុទ្ធតែ សាស្ត្រាចារ្យគាត់ឲ្យអនុសាសន៍យើងថា ឥឡូវយើងត្រូវដាំដំឡូង១មីសម្រាប់ពេលយើង អត់អាទំនាប១យើង ដាក់ស្រូវទៅយើងទៅស្នើស្រូវពីខាងលើម៉ោ ហើយឲ្យទៅធ្វើសេដ្ឋកិច្ចទៀតទំនាក់ទំនងទៀត យើងអ្នក១៧មេសាមែនប៉ុនតែយើងមានខ្នងបង្អែកថ្នាក់មូលដ្ឋាន ដូច្នេះគេកំណត់ថាខ្ញុំនេះថ្នាក់មូលដ្ឋានតែម្តង ។

ដានី ៖ កាលហ្នឹងសាច់ញាតិពូ គេធ្វើខាងអី?

សុត ៖ គេខាងកម្មាភិបាលខាងចលនា ឬក៏ខាងគណៈសហករណ៍ឬក៏ធ្វើការចៅហ្វាយស្រុក តាយ៉ៃ អីវិនដែលគេយកទៅវៃចោលនៅសម័យ៣ឆ្នាំហ្នឹងសុទ្ធតែបងប្អូនខ្ញុំទាំងអស់ តាយ៉ៃ ហើយតា ប៉ុនតាភោគ សារី ថ្នាក់តំបន់ម៉ងសុទ្ធតែបងប្អូនខ្ញុំទាំងអស់ ។

ដានី ៖ អ្ហូ!តាភោគ សារី ខ្ញុំធ្លាប់លឺឈ្មោះគាត់ដែរ?

សុត ៖ បាទ!សុទ្ធតែយកទៅវៃចោលទាំងអស់ ពីដើមគេអត់ហៅតាតុមទេ គេហៅតាភោគសារី ហើយតាយ៉ៃហ្នឹងពូខ្ញុំ ពូជីដូនមួយ ។

ដានី ៖ ដល់ពេលអញ្ចឹងពូមានខ្នងបង្អែក?

សុត ៖ បាទ!មានខ្នងបង្អែកបានគេឲ្យគ្រប់គ្រងកម្លាំងសាស្ត្រាចារ្យ ហើយធ្វើយ៉ាងណាណែនាំគេ ឲ្យគេចេះធ្វើការដើម្បីចិញ្ចឹងជីវិតកសាងជីវិតរបស់ខ្លួន ។

ដានី ៖ ហើយម៉េចទៀតទៅ?

សុត ៖ ដល់ពេលអញ្ចឹងយើងធ្វើបាន យើងដាំអំពៅបាន ដាំដំឡូងបាន ដាំពោតបាន ពោតស ពោតក្រហមដាំបានទាំងអស់ ។

ដានី ៖ បាទ!

សុត ៖ ល្ពៅ ត្រលាច សណ្តែក ត្រសក់ គ្រប់យើងដាំបានទាំងអស់ គ្រប់លទ្ធផលបន្លែដែល យើងធ្វើ គឺវាមានអ្នកឯកទេសរបស់វាច្បាស់លាស់ទាំងអស់ ទាំងអស់ម៉ងពួកហ្នឹងចេះ ទាំងអស់ ដល់អញ្ចឹងអ្នកណាផ្នែកដាំថ្នាំជក់ដាំថ្នាំជក់ ថ្នាំជក់យកអាលេខ១ លេខ២ទៀត ដើម្បីយកទៅផ្គត់ផ្គង់ គេលើ កុំឲ្យគេថាយើងខ្ជិល ហើយអាទី២អ្នកសម្រាប់ធ្វើជៀលធ្វើអី ធ្វើកេះធ្វើអាឡាំង សម្រាប់ៗបេះថ្នាំបុកសម្រាប់ដាក់ស្ករសហ្នឹង ឲ្យមានគ្រប់ផ្នែកទាំងអស់ យើងធ្វើបានមែន ។

ដានី ៖ ១០០នាក់ដាងហ្នឹង?

សុត៖ បាទ!យើងធ្វើបាន ដូច្នេះបន្ថែមតាំងពីចេក តាំងពីតាឡូង តាំងពីពោត តាំងពីត្រលាច ល្ពៅ យើងធ្វើបានទាំងអស់ រាប់មុឺនរាប់សែនក្រុមយើងធ្វើបានសម្បូរព្រៃខុះអីយើងធ្វើ រោង បាទ! អញ្ចឹងយើងមានស៊ីគ្រប់គ្រាន់ ។

ដានី ៖ កាលហ្នឹងក្រុមរបស់ពូបានហូបចុកគ្រាប់គ្រាន់ទេ?

សុត ៖ បាទ!អត់មានដឹងអ្នកណាថាអត់ផង បាទ!តាំងពី៧៥រហូតដល់៧៩យើងអត់ដឹងថាយើង អត់មាន អីហូបផង ។

ដានី ៖ អញ្ចឹងអើកម្លាំង១០០នាក់ហ្នឹងនៅជាមួយពូតាំងពី៧៥រហូតដល់៧៩?

សុត ៖ បាទ!នៅរហូតទល់មក៧៩គឺនាំម៉ោជាមួយទ័ពវាអស់ ។

ដានី ៖ ចុះបញ្ហាអ្នកផ្នែកចំរៀងគេអត់ធ្វើអី?

សុត ៖ ពេលដែលវៀតណាមចូលម៉ោអញ្ចឹងយើងអត់ដឹងអ្នកណាម៉េចទេណា៎ តែលឺសូរថាអាវៀតណាម ចូលមកហើយ យើងចេះតែរត់ម៉ោម៉ងគោក្របីយើងរាប់ រយក្បាល

គោក្របីរាប់រយក្បាលពួក ខ្ញុំអាស៎ មានទាអីវិនគឺអ្នកចិញ្ចឹងផ្សេង គឺមិនបាច់ទៅហូបអីទេគឺថាចិញ្ចឹមមាន់ ទា ក្រៀវខ្លួនឯង អត់មានពិបាកយកពីណាម៉ោទេ ។

ដានី ៖ ចុះពូដល់ពេលកាលជំនាន់៧៧-៧៨ហ្នឹងគេមិនចាប់ៗអើ តាភោគ សារី តាអាយ៉ៃពូមានដឹងទេ?

សុត ៖ ដឹង

ដានី ៖ បាទ!ចុះអត់មានប៉ះពាល់ដល់ពូទេ?

សុត ៖ អត់ទេ គេចាប់ៗតាភោគ សារី កាល៧៧-៧៨គេចាប់តែ ភោគ សារី កម្មាភិបាលគេ ដាក់ម៉ោពីរភូមិភាគ ភូមិភាគមួយគេហៅភូមិភាគនិរតី ភូមិភាគពីរគេហៅភូមិភាគ បញ្ចឹមមកដាក់នៅពាយ៉ប្រយើងនេះ ក៏ប៉ុន្តែគ្រាន់តែគេមកដល់ភ្លាមយើងជ្រែភ្លាម យើងហៅប្រជុំទាំងអស់យុវជនទាំងអស់ដែលមកនៅកងកម្លាំងរបស់យើង ហើយយើងកុហកប្រវត្តិរូបរបស់យើងតែម្តង ។

ដានី ៖ ដើម្បីអី?

សុត ៖ ដើម្បីៗរួចខ្លួនទាំងអស់គ្នា ព្រោះបងប្អូនបើក្រៅពីខ្ញុំបងប្អូនគេយកទៅវៃចោលទាំងអស់អត់ទុកទេ ។

ដានី ៖ ពូប្រាប់អញ្ចឹងដែរ?

សុត ៖ ហ្នឹងហើយ ដូច្នេះខ្ញុំហ្នឹងដែលពេលនេះគេវៃចោលទាំងអស់ដូចគ្នា ដូច្នេះយើងត្រូវរក វិធីសាស្រ្តយ៉ាងម៉េចដើម្បីឲ្យរួចខ្លួនទាំងអស់គ្នា អញ្ចឹងលាក់ប្រវត្តិរូបម៉ង អត់មានបងប្អូន ណាប្រាប់ទេ ១៧មេសាសុទ្ធសាធម៉ង ។

ដានី ៖ ដល់ពេលហ្នឹងពូប្រាប់ថាពូ១៧មេសាដែរ?

សុត ៖ ១៧មេសា

ដានី ៖ គេជឿដែរ?

សុត ៖ ជឿ គេជឿព្រោះពួកហ្នឹងម៉ោអត់ដឹងអីផង ។

ដានី ៖ ពួកហ្នឹងអត់ដឹងតែពូអ្នកគ្រប់គ្រងគេ គេជឿដែរ?

សុត ៖ គេជឿ ពួកហ្នឹងតាសនអី អីណាអី ម៉ោពីខាងគណៈស្រុកគេម៉ោពីខាងនិរតី ។

ដានី ៖ អ្ហូ!មកជួប ស្គាល់ពូ?

សុត ៖ មកជួបនៅហ្នឹង ស្គាល់នៅហ្នឹង ។

ដានី ៖ ឈ្មោះអី?

សុត ៈ ឈ្មោះតាសនមួយ ហើយចៅហ្វាស្រុកគេនោះឈ្មោះអីគេទេភ្លេចហើយ ដល់ពេលគេម៉ោ គេអត់ហានទម្លាក់យើងទេ គេឲ្យប្រជាជនរើស គេមកដល់គេធ្វើម៉ោធ្វើការពួកគេម៉ោ៥-៦នាក់មកកន្លែងនេះនៅដាច់ដោយឡែកពីប្រជាជន ដល់អញ្ចឹងគេមកដល់គេប្រជុំថាឲ្យ ជ្រើសរើសតើកម្មាភិបាលដែលដឹកនាំហ្នឹងធ្វើអំពើអ្វីខ្លះទៅលើយើង គេឲ្យអនុម័តដល់ ហ្នឹងគេថាកម្មាភិបាលដែលចាស់ដែលខូចម្នាក់នោះទៅបាត់ហើយ ។

ដានី ៈ អ្នកណាគេកាលហ្នឹង?

សុត ៈ ឈ្មោះស្អីរត់ទៅបាត់ហើយ ជំនាន់ហ្នឹងវាសុទ្ធតែខូចខិលប៉ុណ្ណឹងនៅសុទ្ធតែអ្នកដែលត្រូវគេសម្លាប់ចោលទាំងអស់ គេឲ្យជ្រើសរើស ។

ដានី ៈ ដល់អញ្ចឹងគេជ្រើសរើសអ្នកណា?

សុត ៈ គេជ្រើសរើសខ្ញុំដដែល ។

ដានី ៈ គេឲ្យធ្វើប្រធានកងចល័តទាំង១០០នាក់ហ្នឹងឬគេឲ្យគ្រប់គ្រងអីទៀត?

សុត ៈ ហ្នឹងហើយគេឲ្យគ្រប់គ្រងម៉ង គ្រប់គ្រងដដែល ។

ដានី ៈ គេហៅកងចល័តអីកាលហ្នឹង?

សុត ៈ គេហៅកងចល័តស្រុក៧០ ។

ដានី ៈ ស្រុក៧០ហ្នឹងឥឡូវគេហៅស្រុកអីគេ?

សុត ៈ ឥឡូវគេហៅស្រុកបរិល

ដានី ៈ ស្រុក៧០គេហៅស្រុកបរិលហ្នឹង?

សុត ៈ បាទ!ពីដើមគ្មានអ្នកណាហៅស្រុកបរិលទេ គេហៅស្រុក៧០ ។

ដានី ៈ កាលមុនហ្នឹងតាយ៉ៃគាត់អ្នកនៅ?

សុត ៈ តាយ៉ៃគាត់៦០-៧០ ។

ដានី ៈ ពេលគេចាប់គាត់ទៅពួកខាងនិរតី ខាងបញ្ចឹមម៉ោឈ្មោះតាអី យាយ?

សុត ៈ ឈ្មោះយាយ សន អ្នកគ្រប់គ្រងចល័តស្រុកនោះ ។

ដានី ៈ ហើយគណៈស្រុកយើង?

សុត ៈ ហើយគណៈស្រុកយើង កាលមុនជួបគាត់នៅឆ្នាំ៧៨ នៅ១១៣ ។

ដានី ៈ គាត់ឈ្មោះអីដែរ?

សុត ៈ ឈ្មោះតាអេន

ដានី ៖ ខាងហ្នឹងខ្ញុំអត់ស្គាល់ទេ ខ្ញុំស្គាល់ខាងព្រះនេត្រព្រះ ឈ្មោះយាយថែម យាយថែមគាត់មៅខាងនិរតីដែរ?

សុត ៖ យាយថែមគាត់ម៉ោខាងនិរតី ។

ដានី ៖ យាយថែមគាត់ម៉ោខាងនិរតី យាយថែមគេស្គាស់ ដល់ពេលអញ្ចឹងយើងស្គាល់ដល់អញ្ចឹងយើងស្គាល់តាមគេដែរ?

សុត ៖ កាលហ្នឹងមានតែយាយ ថែម ហើយនឹងតាអែមៗ ខ្មៅ ។

ដានី ៖ តើឥឡូវគាត់នៅណា?

សុត ៖ នៅគីឡូ១៣ហ្នឹង តែមិនស្លាប់ឬរស់ទេឥឡូវគាត់ចាស់ហើយ

ដានី ៖ គីឡូ១៣នៅខាងស្រុកម៉ាឡៃយើងដែរ?

សុត ៖ អត់ទេស្រុកសំពៅលូន ។

ដានី ៖ អញ្ចឹងគាត់អត់អីទេ គាត់អ្នកគ្រប់គ្រង?

សុត ៖ ខ្ញុំមិនដឹងដែរព្រោះខ្ញុំនៅឆ្ងាយ អត់ដឹងរឿងហេតុអីទាំងអស់ ។

ដានី ៖ ចុះពូមានដែលបានជួយនិស្សិតបញ្ញាវ័នដែលម៉ោនៅក្នុងកងពូ ពូមានដែលបានជួយសង្គ្រោះពីណាឲ្យរួចពីការគេចាប់ ពូមានបានការពារអី?

សុត ៖ ឥឡូវខ្ញុំនិយាយៗទៅតាមការជាក់ស្តែងអំពីសម័យនោះៗ កន្លែងខ្ញុំអត់មានអ្នកណាចាប់អីសោះ ព្រោះរបាយការណ៍លើខ្ញុំ ខ្ញុំរាយការណ៍ថាអត់មានគឺអត់ហើយ គេថាមួយខែគេឲ្យរាយការណ៍មួយម្តងតែនរណាដែលគេហៅថាមិនធ្វើការ ហើយរាយការណ៍គឺថារបស់យើងល្អទាំងអស់ល្អ វាស្របទៅតាមលទ្ធផលដែលយើងធ្វើបានទាំងអស់ ព្រោះលទ្ធផលដែលយើងធ្វើបានដូចថាអ្នកណាចង់បានថ្នាំ អ្នកណាចង់បានស្ករដែន អ្នកណាចង់បានស្ករ ពាងអ្នកណាចង់បានស្ករសអី ហើយអ្នកណាចង់បានចេក តំបន់ណាខ្លះចង់បានអីគឺយើងផ្តល់ឲ្យទាំងអស់ ប៉ុនយើងប្តូររបស់ យកមកប្រើប្រាស់នៅក្នុងកន្លែងយើង ហើយបើថាចង់បានស្ករដូរគ្នាម៉ាសំពៅ ដូចថា៥គោន ទៅ៥គោនម៉ោប៊ិនបានអញ្ចឹងអត់ឲ្យទេ វាចង់ស៊ីរបស់យើងៗអត់ឲ្យទេ ខ្លួនទីពឹងខ្លួនអ្នកណាធ្វើ ប៉ុនណ្ណាបានប៉ុនណ្ណឹងស៊ីត្រង់ហ្នឹង ។

ដានី ៖ ចុះនៅក្នុងក្រុមពូជាង១០០នាក់គាត់ខំប្រឹងប្រែងធ្វើការទាំងអស់គ្នា ឬមានអ្នកមានបញ្ហា ដែរ?

សុត ៖ អត់ដែលមានទេ ឈឺក៏ពិតមែនតែយើងមានពេទ្យ យើងមានសង្គមកិច្ចយើងមានពេទ្យស្នើពីខាងលើម៉ោ យើងស្នើម៉ោគ្រប់ពេលអត់ឲ្យមានបញ្ហា ។

ដានី ៖ ចុះការហូបចុកអីម៉េចបានយើងហូបបាន ហូបអីឬក៏ហូបបបរ?

សុត ៖ ខ្ញុំដូចជាមិនដែលហូបបបរផង ព្រោះគេថាឲ្យហូបបបរពេលដែលវាម៉ោអញ្ចឹងបបរឲ្យហែងស៊ីទៅ បបរ ប៉ិនតែហែងទៅវិញអញស៊ីបាយ គេដូររហូតដូចថាចៅហ្វាយស្រុកគេចង់បានអង្ករប៉ុន្មាន ៣តោន យើងសុំអង្ករចំនួន៤០បាវឲ្យទៀត ។

ដានី ៖ ចុះគេអត់ថាអីទេ?

សុត ៖ អត់ទេ ចុះអាហ្នឹងយើងធៀបថារបបផ្លាស់ប្តូរ បើយើងធ្វើមិនបានដូររបស់យើង យើងស៊ីរបស់យើងទៅ ។

ដានី ៖ ចុះអត់មានថាអេស៎ប្រជាជនគេហូបអត់នេះ?

សុត ៖ អត់ទេ!យើងឲ្យដែរ ពេលដែលគេស្នើសម្រាប់ប្រជាជនឬសម្រាប់អ្នកដទៃ យើងឲ្យទៅឲ្យ ពាក់កណ្តាលឬក៏ជាងពាក់កណ្តាលទៅឲ្យទៅគេ ដោយយើងមិនយកអាអ៊ីទេ របស់ណា ដែលយើងអត់យើងយកទៅដូរវិញ យើងឆ្លាតដែលយើងមិនឆ្លាតគេអត់នៅបើយើងមិន ឆ្លាតងាប់យើងងាប់ប្រជាជនទៀត ។

ដានី ៖ បាទ!ចុះអ្នកដែលក្នុង១០០នាក់ហ្នឹង មានអ្នកណាដែលឆ្នាំ៧៩រត់មកតាមពូ ហើយនៅស្រុកយើង?

សុត ៖ នៅនេះដូចអត់មានទេ!ទៅ ៧៩មកនេះនៅកងខ្ញុំម៉ោច្រើនដែរ ដូចអ្នករឹម ដូចអាម៉ៅ ម៉ោដូចច្រើនដែរ ក៏ប៉ុន្តែគេឡើងទៅអាមេរិកទាំងអស់ពួកហ្នឹង គេបបួលដែរតែយើងអត់ ទៅ ទៅទាំងអស់ជាប់ប្រហែលជិត១០០នាក់ ។

ដានី ៖ កាលហ្នឹងរត់មកជាមួយពូច្រើន?

សុត ៖ រត់មកទាំងអស់ រត់មកព្រំដែនទាំងអស់គ្នា ប៉ុនគេចេះគេៗនេះយើងដែរហ្នឹង គេថាបងឯងតាម ទៅប្រទេសទី៣ ព្រោះខ្ញុំមិនស្គាល់ប្រទេសទី៣ដូចគេ គេៗរៀនខ្ពស់ជាងយើងគេដឹងជាងយើង អាស៎ ខ្ញុំថាអញទៅមិនរួចទេណា៎ យើងមិនដឹងថាគេទៅត្រួសៗអានេះជាកម្មរបស់យើងទេណា៎ ។

ដានី ៖ ពូខ្ញុំចង់ដឹងបន្តិចពី៧៩ រត់យ៉ាងម៉េចពេលរត់ដំបូងពេលយួនចូលម៉ោ ម៉េចមូលហេតុអី បាន?

សុត ៖ ពេលលឺថាអ៊ូយួនម៉ោហើយ យើងចេះតែនាំគ្នារត់ទៅៗមានគោមានក្របីទៅនោះ រត់កាត់ភ្នំទៅនោះ ឆ្លងកាត់វាល១០ទៅគេហៅព្នងគួយទៅពីផ្ទះទៅម៉ង ពេលទៅហ្នឹងឆ្លងស្ពានធំ ភ្នំកន្ទួងឆ្លងកាត់ផ្លូវជាតិលេខ១០ទៅ ទាំងគោក្របីចេះតែដើរទៅហើយ ។

ដានី ៖ មូលហេតុអីបានជាយើងរត់ ពូខ្លាចអីគេ?

សុត : យេីងមិនដឹងៗថាការកាប់សម្លាប់អីម៉េចយេីងមិនដឹងទេណា៎ គេថាអានេះប្រេីលតាមគ្នា អ្នកខ្លះគេចេញដែរ ស្រីៗខ្លះចេញដែរតែអ្នកកងចល័តគេចាស់ទេណា៎ ដែលចេញពីកងចល័តខាងក្នុងម៉ោ អ្នកម៉ោខ្លះគេទៅវិញ ប្រសិនជាម៉ោទាំងអស់មិនតិចទេ មិន១០០នាក់ទេជាប់១០០០នាក់តែអាអ្នកទៅវិញជាងទេ្៤ភាគ ហេីយខ្ញុំធម្មតាធ្វេីមេគេផង ត្រូវតែហេីយទោះជាលំបាក ម៉េចក៏ត្រូវតែម៉ោដែរ វងអង្គការគេហៅវងអង្គការ ។

ដានី : ចុះស្ថានភាពពេលរត់ហ្នឹងយ៉ាងម៉េចដែរ ពូជួបការលំបាកយ៉ាងម៉េចហេីយពូនៅកងចល័តដដែល ឬក៏មានការផ្លាស់ប្តូរទៅជាកងទ័ពវិញយ៉ាងម៉េច?

សុត : បាទ!ដល់ពេលម៉ោហ្នឹង ម៉ោដល់យេីងជ្រលងព្នួយហ្នឹងៗគេយកគេហៅមិនដឹងថ្នាក់ណាគេហៅៗដូចយេីងនៅក្រោមដូចថាតាផល ឈ្មោះផលគេធ្វេីមេកងចល័តធំ នៅខាងការដ្ឋានធំនៅជុំវិញ ស្រុក៧០ ចេះតែហៅម៉ោឡេីងម៉ោសំឡូតៗគេហៅយុវជន យុវនារីទាំងអស់ឡេីងមកសំឡូតវិញ ម៉ោដល់គេឲ្យដាំបាយស៊ីហេីយគេបេីកអាវុធឲ្យដេីម្បីទប់ទល់វៀតណាមទប់ទល់យួនរត់ទៅណាទៀតឥឡូវរត់ដល់អង្គកាហេីយ ដល់ពេលហ្នឹងហេីយយេីងចាប់ផ្តេីមត្រៀមអាវុធស្លាប់ មិនមានទាំងអស់គ្នាទេណាស់១០នាក់មានអាវុធមួយដេីមដល់ពេលនេះហេីយព្រឹកឡេីងគេឲ្យ ម៉ោកន្លែងដងទង់យេីងៗនៅជិតដីក្រែង នៅស្រុកសំឡូតហ្នឹង ឲ្យមកសម្រាកនៅខេត្ត សម្រាក ធ្វេីដូចកងទ័ពអញ្ចឹងប៉ុន្តែអត់មានអាវុធទេមានអាវុធតែមួយដេីមក្នុងមួយក្រុម មួយក្រុមមាន តែមួយនាក់ហ្នឹង អ្នកណាមេក្រុមគេមានទៅ ដូចខ្ញុំកាលហ្នឹងគេឲ្យធ្វេីមេកងមានមួយដេីមដែរ ។

ដានី : ហេីយម៉េចទៅ?

សុត : ដល់ពេលអញ្ចឹងគេឲ្យរៀនសូត្រទៅ មេកងពលគេហៅរៀនសូត្រគេអត់ស្គាល់មុខទេ តែគេព្រោះគ្នាវាច្រេីនគេឲ្យរៀនសូត្រគេណែនាំអញ្ចឹង ហេីយគេឲ្យម៉ោចុះមកប្រយុទ្ធ ឲ្យម៉ោ ប្រយុទ្ធត្រូវ ឲ្យម៉ោប្រយុទ្ធខាងជេីងផ្លូវជាតិលេខ១០ហ្នឹងគឺកងមជ្ឈិមគេនោះណាមានរថក្រោះទៅរ៉ៃទៅខាងបាត់ដំបង ហេីយយេីងនេះចុះទៅខាងជេីងផ្លូវ ជាតិលេខ១០ នៅម្តុំយេីងនេះគេហៅ (ស្តាប់មិនបាន) ហេីយកាំភ្លេីងអត់មានទេ ដូច្នេះគេថា ធម្មតាអ្នកកេនឈ្លបស្តាប់ឲ្យច្បាស់គឺយេីង ទាំងអស់គ្នាយេីងមិនមែនធ្វេីប្រធានឈ្លបទេ ដូច្នេះប្រធានឈ្លបគេថា ១ដេីមឲ្យបាន១០ដេីម ឲ្យបាន២០ដេីមឲ្យបានគ្រប់គ្នា ។

ដានី : បាទ!ធ្វេីម៉េចទៅឲ្យបានគ្រប់គ្នា?

សុត ៖ វ៉ៃពីខ្មាំងហើយយកមកផ្ទះខ្លួនឯង នេះជាពាក្យប្រដៅរបស់គេណាស់ អញ្ចឹងយើងក៏ធ្វើ តាមគេ មេវរៈហ្នឹងទៅ ដឹម៉ោនេះមានមេវរៈគេ មេវរៈគេសុទ្ធតែពួកនិរតីទាំងអស់ ដូច តាងែតមួយ ប្រធានវរៈនៅនោះ ហើយមួយទៀតឈ្មោះតាឆន១ ប្រធានតំបន់គេហ្នឹង ។

ដានី ៖ តំបន់ណា?

សុត ៖ ជាប្រធានតំបន់៣ ប៉ុនតែពួកម៉ោពីនីរតីទាំងអស់ហ្នឹង ។

ដានី ៖ ពួកក្រោយ?

សុត ៖ ពួកក្រោយហើយ ពួកខ្ញុំមុនគេចាប់អស់ហើយ ហើយអានេះសុទ្ធតែពួកម៉ោក្រោយហើយ មានប្រធានគេឈ្មោះតាឆន ហើយនឹងតាងែតមួយប្រធានយោធាតំបន់ ប៉ុនយើងមកនៅ នេះយើងជាអ្នកយោធាមួយក្រុមដែល ។

ដានី ៖ កាលហ្នឹងពេលប្រយុទ្ធមានការពិបាកឬក៏ស្រណុកកាលហ្នឹង?

សុត ៖ អារឿងប្រយុទ្ធហ្នឹងទី១ វាពិបាកហើយ ទី២ អាការរស់នៅដែលយើងសម្រាកហ្នឹងក៏ វាមិនស្រួលដែរព្រោះក្នុងព្រៃ ដឹកក្រឡុកត្រង់សេដេកពេលយប់មានទៅស្រួលអី គេហៅថាការតស៊ូមិនស្រួលណា ។

ដានី ៖ បាទៗ ៗ! ហើយម៉េចទៀតទៅ?

សុត ៖ ហើយដល់ពេលក្រោយម៉ោក៏វៀតណាមហ្នឹង ចាប់ផ្ដើមបើកយុទ្ធនាការណ៍ វ៉ៃបុកកំទិចខ្មែរក្រហមពីក្នុងព្រៃ វ៉ៃចេញពីខាងលិចបាត់អស់ បុកម៉ោក្លោងទ្វារធំ ហើយពួកខ្ញុំចេះ តែថយៗ មៅៗរហូតមកដល់ព្រំដែនម៉ោរហូតប្រហែលមួយខែគ្មានកាន់អាវុធអីទេ ស្លាប់ ខ្លះរត់រួចខ្លះ ។

ដានី ៖ ហើយដល់ពេលដកថយដល់ណាទៅ?

សុត ៖ មកដល់ខ្លែនចុះដេញៗម៉ោរហូត អាពីចំហៀងក៏វ៉ៃ អាពីមុខក៏វ៉ៃពីបាត់ដំបង ដូច្នេះរត់មកជួបជុំគ្នានៅខ្លែន ។

ដានី ៖ ហើយកន្លែងហ្នឹងយ៉ាងម៉េចទៅ?

សុត ៖ កន្លែងនោះមនុស្សច្រើនណាស់ សុទ្ធតែទាហានម៉ង់ អាលើងផងអាខ្មៅផងអាខៀវផង ។

ដានី ៖ មានច្រើនពណ៌? ពណ៌អីខ្លះទៅមានពណ៌នៅតាមភូមិភាគអាហ្នឹង?

សុត ៖ តាមភូមិគេតាមពណ៌ភូមិភាគរបស់គេដែរ បើតាមភូមិភាគគេពណ៌រាងដូចចេះទៅរាងអាច់ សេះអាខ្លះរាងពណ៌ខៀវផ្ទៃមេឃទៅ ហើយបើពួកយើងគេចាត់ខ្មៅទាំងអស់ទៅ ។

ដានី ៖ ពួកណាហ្នឹង ពួកបាត់ដំបង?

សុត ៖ ពួកខាងតំបន់គេចាត់ខ្មៅសុទ្ធអញ្ចឹងទៅ ។

ដានី ៖ តំបន់តាឆនតាអីម៉ោហ្នឹងទាំងអស់?

សុត ៖ តាឆនហ្នឹងហើយម៉ោទាំងអស់ទាំងមេវរៈម៉ោទាំងអស់ ។

ដានី ៖ ចុះប្រដាប់ប្រដារគេរៀចចំម៉េចទៅ?

សុត ៖ មកដល់ខ្សែនក៏គេឲ្យសម្រាកនៅព្រំដែន ៣-៤-៥ថ្ងៃបានដល់ម៉ាអាទិត្យទើបគេជ្រេ គេជ្រេកម្លាំងប្រហែលជាខែ៣-៤-៥ហើយឆ្នាំ៧៩ហ្នឹង គេឲ្យយើងមកឈរជើងនៅអូហ៊ីសកណ្ដាល កន្លែងហ្នឹងកន្លែងកាប៊ីនគេហៅភ្នំពេជ្រកណ្ដាល មេរៀនយើងមិនបានរៀន គេមានតែមេក្រុម និងមេកងទេដែលបានរៀន ហើយគេឲ្យយើងមកប្រចាំការនៅ៧ខាងដើមវិញ ។

ដានី ៖ កាលហ្នឹងគេមានបានបែងចែកជាក្រុមឬជាកងទេ?

សុត ៖ អត់ទេជាកង កងណានៅកងហ្នឹងដដែល ខ្ញុំម៉ាវរៈនៅម៉ាវរៈធំដដែល ។

ដានី ៖ បាទ!វរៈសេនាធំលេខប៉ុន្មាន?

សុត ៖ មិនមានលេខទេ សម្រាប់ក្រុមតាឆន តាង៉ែត ប៉ុនតាង៉ែតងាប់ហើយនៅតែតាឆន ដូន កាលងាប់អស់ហើយមើលទៅព្រោះចាស់ៗ ។

ដានី ៖ ចុះអត់មានកងពលទេ?

សុត ៖ កងពលក៏មានដែល មានកងពលតាកន តាជន ខ្ញុំអត់ស្គាល់តាកនទេ ខ្ញុំស្គាល់តែតាជនកាលហ្នឹង តាកនមកក្រោយខ្ញុំទៅទើបឃើញតាកនម៉ោ ។

ដានី ៖ ចុះកងពលតាជនលេខប៉ុន្មាន?

សុត ៖ កងពលលេខ១កងពលធំ ។

ដានី ៖ ចុះដល់ពេលហ្នឹងអ្នកពិលប្រាំដើមធ្វើម៉េចទៅ?

សុត ៖ យើងនៅហ្នឹងយើងនៅការពារហ្នឹងកុំឲ្យទ័ពរដ្ឋកម្ពុជាឬទ័ពវៀតណាមម៉ោ បើវាម៉ោក៏បក្សនៅនេះបញ្ជូនទៅវិញក៏ទៅដល់ពេលធ្វើយើងមិនឈ្នះទៅ យុទ្ធនាការណ៍មួយសារទៀត ដូចអាកាល ជិតបាត់ដំបងអញ្ចឹង យុទ្ធនាការណ៍ធំ កាំភ្លើងធំ មានរថក្រោះម៉ោយើងទៅដកថយមកវិញម៉ោ ថយម៉ោលើកក្រោយនេះប្រហែលជាខែ៧ ។

ដានី ៖ ៧៩ដែល?

សុត ៖ ៧៩ដែលប្រហែលជាខែ៧ ចុះនៅក្នុងឡាគីពីរបីខែហ្នឹង ដំពេលវ៉ៃខ្លាំងយើងដកចេញយើងមានអាវុធអីទប់ទល់ វានៅតែចូលម៉ោ យើងដកចេញកុំឲ្យតែត្រូវរបួសបានហើយមានអាមេ ណាទប់បានបើកូនទប់មិនបានអាមេក៏រត់ដូចតែគ្នា យើងយករួចខ្លួន មេនៅ

តែក្រោយ គាកូនថា ទៅហើយអាមេកាលនោះសម័យនោះយោធាយើង គេហៅថា ទាហានយើងសព្វថ្ងៃហ្នឹង ទាហានពីអតីតកាលហ្នឹង គាម៉ោទៅហើយតែមេហានប្រឆាំងវៃ បាញ់វាចោលទៀត គេទប់មិន ឈ្នះហើយខ្លាំងអីតែឯងបាញ់មេចោលទៀត ចុះបើ គេទប់មិនឈ្នះទៅហើយខ្លាំងអីតែឯងបាញ់ មេចោលទៀត អត់ហានទេ មិនដូចសម័យ ៣ឆ្នាំទេ ៧៩អត់ហានជាមួយកូនទេ គាកូនថាទប់ មិនជាប់ហើយ មេទប់តែឯងមើលបើ ពូកែអត់ហានទេ ដូច្នេះនិយាយឲ្យហើយបើថាហានតែ សម្លាប់តែកូនទាហានក្នុងក្រុមមួយ គឺអ្នកឯងក៏អត់រួចខ្លួនដែល អាមេប៉ុណ្ណាក៏ដោយដឹងអញ្ចឹងអត់ ហានទេ ។

ដានី ៖ ហើយម៉េចទៀត?

សុត ៖ ដល់ម៉ោៗសម្រាកៗហើយគេហៅមកធ្វើការនៅបឹងប៉េងយើងនេះ ទាំងអស់មាកងពួកខ្ញុំ មាកង វរៈម៉ោទាំងអស់កងវរៈគាឆនម៉ោទាំងអស់ ម៉ោបឹងប៉េងនេះៗម៉ោប្រជុំហ្នឹង គាជនគេហៅមក ប្រជុំ ពីដើមខ្ញុំស្គាល់តែគាជនទេភូមិភាគពាយ័ព្យ គាកនមិនទាន់ម៉ោ អត់ស្គាល់ទេមិនដឹងម៉ោពីណា ។

ដានី ៖ គាជនគាត់នៅពាយ័ព្យ?

សុត ៖ គាត់នៅពាយ័ព្យនៅហ្នឹងរហូតពីដើម ។

ដានី ៖ គាត់នៅធ្វើអីនៅហ្នឹង?

សុត ៖ គាត់កងពលរហូតកងពលទីមួយរហូត នៅប្រចាំព្រំដែននៅប៉ៃកខាងលិចហ្នឹង ចាប់ពីប៉ៃលិន មកទល់យើងនេះ ។

ដានី ៖ អ៊ូ!កាលជំនាន់៣ឆ្នាំ?

សុត ៖ ៣ឆ្នាំគាត់ប្រចាំនៅហ្នឹង

ដានី ៖ គាត់មកពីស្រុកណាម៉ោ?

សុត ៖ គាត់នៅហ្នឹងម៉ងនៅពាយ័ព្យហ្នឹង ។

ដានី ៖ អញ្ចឹងហើយម៉េចទៀតទៅ?

សុត ៖ ដល់ពេលហ្នឹងគាត់ប្រជុំហៅទៅធ្វើការនៅបឹងប៉េងមួយថ្ងៃ កាលហ្នឹងវានៅអាស្រុកសាមគ្គី នៅមុខស្រះបឹងប៉េង ហៅឲ្យមៅប្រជុំមាអាទិត្យម្ដងអញ្ចឹងវាថាឥឡូវពួកឯង មាវរៈនេះ ស្រឡាញ់គឺ ថាម៉ោហើយឈប់ឲ្យឯងទៅហើយ ឲ្យឯងទៅនៅជាមួយពូភាពម្ដង អត់ស្គាល់ សុភាពទេ សុភាព សព្វថ្ងៃនេះ ។

ដានី ៖ បាទៗ!

សុត ៖ ហើយកាលហ្នឹងវាខ្វះកម្លាំង ព្រោះភាពហ្នឹងវាវរៈសេនាតូច វាអត់ទាន់គ្រប់កម្លាំងដូចវរៈ សេនាធំ នៅខ្វះពួកយើងមួយវរៈសេនាតូច ឥឡូវពួកឯងមាវរៈសេនាតូចទៅនៅជួយតាភាពមាវរៈសេនាតូច ចាប់ពីប៉ៃយប៉ែតមកនេះ មកទល់បឹងប៉េងហ្នឹង ។

ដានី ៖ បាទ!អញ្ចឹងតាជនគាត់ទៅនៅណាទៅ?

សុត ៖ ហើយតាជនគាត់នៅហ្នឹងកាន់កងពល កាលហ្នឹងគាត់ក្ដាប់កងពលតាំងពីប៉ៃយប៉ែតមករហូត មកទល់នឹងប៉ៃលិន វរៈសេនាធំពីរបីអញ្ចឹងទៅ វរៈសេនាធំប្រធាន វរៈសេនាធំ១១ វរៈសេនាធំស៊ីងហាវ វរៈសេនាធំផ្សេងៗរហូតអញ្ចឹងទៅ ។

ដានី ៖ សុទ្ធតែកងពល?

សុត ៖ តាភាពគាត់នៅវរៈសេនាធំ គាត់មិនមែននៅកងពលទេ

ដានី ៖ ចុះពូកាត់ព្រៃមកចូលនៅ?

សុត ៖ ខ្ញុំៗកាត់ព្រៃមកនៅម្ដុំហ្នឹងរហូតទៅ តាំងពីខែ៧មកម្ល៉េះសុទ្ធតែព្រៃរហូតគឺគ្មានស្អីទេ ព្រៃរហូតតែម្ដងព្រៃគឺដើរទៅតាកខាំ ។

ដានី ៖ តាក?

សុត ៖ បាទ!តាកខាំតែម្ដង សុទ្ធតែតាកអត់ដឹងថាខាំហើយអត់ដឹងទេ តែឈាមពេញជើងអស់ ព្រៃអត់ហានកាប់នៅទេ នៅតែតាមមាត់អូរ ។

ដានី ៖ ព្រៃដើមអីគេឈើហ្នឹង?

សុត ៖ អាដើមឈើយើងព្រៃស្រោបនោះបាទ ស្រឡៅ ប៉េង ឈើទាល គគីរ

ដានី ៖ តាំងពីខែ៧ ឆ្នាំ៧៩?

សុត ៖ បាទ!តាំងពីខែ៧ ឆ្នាំ៧៩មករហូតមកទល់ឥឡូវនេះ ។

ដានី ៖ ហើយដល់អញ្ចឹងពេលពូកាត់ចូលក្នុងវរៈសេនាធំរបស់តាភាពទៅ តាជនគាត់?

សុត ៖ បាទ!តាជនគាត់នៅកាន់កងពលដដែល ។

ដានី ៖ កងពលហ្នឹងនៅណាទៅ?

សុត ៖ ទីតាំងនៅឯបឹងប៉េង នៅឯភ្នំដី គាត់កាប់រូមតែម្ដង ។

ដានី ៖ អញ្ចឹងកាលហ្នឹងសុទ្ធតែព្រៃទាំងអស់ អត់វាលអញ្ចឹងទេ?

សុត ៖ អត់ទេ!មានតែផ្លូវដើរតាមព្រំដែនអញ្ចឹងមួយផ្លូវៗ ។

ដានី ៖ ចុះម៉េចទៅការរស់នៅម៉េចទៅដូចថាកងទ័ពរស់នៅតាមព្រំដែន?

សុត ៖ រឿងកង់ទ័ពគេមិនឲ្យយើងអត់ទេណា ទី១រឿងហូបចុកគេមិនឲ្យយើងអត់ទេ ទី២បញ្ហា ស្លៀកពាក់អត់ឲ្យយើងអត់ទេ ទី៣បញ្ហាការយើងរស់នៅប្រចាំ ថ្ងៃគឺយើងមានមុង មានអីគេបើកឲ្យយើងទាំងអស់ សំពត់កៅស៊ូអីមិនមានជាអីទេ សំពត់កៅស៊ូម៉ាគីបបួនៗ គេចង់ម្នាក់ៗគេធ្វើផ្ទះនៅពីក្រោមដើមឈើ ។

ដានី ៖ ធ្វើផ្ទះដែរ?

សុត ៖ ផ្ទះអាសំពត់កៅស៊ូ ។

ដានី ៖ ប្រោះតង់អីជាសំពត់កៅស៊ូ?

សុត ៖ បាទ!ជាសំពត់កៅស៊ូ ។

ដានី ៖ នៅបានប៉ុន្មាននាក់ទៅ?

សុត ៖ គេនៅបើថាយើង៣នាក់ៗម៉ាពួកគេព័ទ្ធកៅស៊ូ៣ គេកាប់ឈើចងអញ្ចឹងម៉ោ ទាញអញ្ចឹងទៅទាញជិតឈើងដេកលក់ស្រួល ។

ដានី ៖ អត់អីទេ?

សុត ៖ អត់អីទេ អត់មានមិនបាច់ធ្វើខ្ទមធ្វើអីណាស័ង្កសីប្រកអត់ទេ កៅស៊ូម៉ង ។

ដានី ៖ ចុះពេលហូបបាយហូបអីម៉េចទៅ?

សុត ៖ ពេលហូបបាយយើងហូបជាក្រុមៗ ដូចថាម៉ាពួកៗអញ្ចឹងទៅ៣ពួកម៉ាក្រុមវាហូបម៉ា ក្រុមអញ្ចឹងទៅ កន្លែងណាវាណាត់គ្នាយើងហូបម៉ាៗកងតូចទៅណាស់ជិត៣០នាក់ទៅ ។

ដានី ៖ យើងដាំអីនៅក្នុងហ្នឹងឬក៏គេយកម៉ោ?

សុត ៖ អត់ទេយើងដាំខ្លួនយើង ប្រមែលម្នាក់មួយសឹកខ្ទះគ្រប់តែគ្នាប្រមែល យើងដាំយើង មិនទាន់មានឆ្នាំងធំនៅឡើយទេ នៅប្រមែលៗទេពី៧៩នៅប្រមែល ពីអាមេរិកកាំង នោះណាំដាំហើយ មិនចាំបាច់នេះទេដាក់តែទឹកហើយដីងតែឆ្អិនហើយ ឆ្អិនយកម៉ោយើង ធ្វើតែម្ហូបទេហើយម្ហូបមានអីត្រីខអី គេឲ្យម៉ោប្រហុកអំបិលអី ។

ដានី ៖ ចុះកាលហ្នឹងមានតែកងទ័ពទេ អត់មានប្រជាជនទេ?

សុត ៖ អត់មានទេ មានតែម៉ុំយើងនេះកាលជិតទាន់ហ្នឹងអត់មានប្រជាជនទេ មានតែអ្នកដឹកជញ្ជូន នារីដឹកជញ្ជូន ដូចយាយខ្ញុំអញ្ចឹងគាត់នៅដឹកជញ្ជូន តែមានអាវុធដូចគ្នាទុកការពារខ្លួន ។

ដានី ៖ ដឹកជញ្ជូនៗអីគេ?

សុត ៖ ពេលដឹកជញ្ជូនយើងនៅតាមដូចថារៀបហ្នឹងទៅម៉ាកងធំទៅ៩៣ទៅ ម៉ាកងធំទៅអូរសាលាត់ទៅ ម៉ាកងធំទៅអូរសាពន្ទ័ម៉ាកងធំទៅរហូតដល់កងវរៈសេនា ដូចកងវរៈសេនាតូចរៀបអញ្ចឹងរហូតទៅ ហើយដល់ពេលនេះប្រាក់ខែគេយកឲ្យតាំងពីអង្គរតាំងពីអី ។

ដានី ៖ ប៉ុន្តែខាងដឹកជញ្ជូនហ្នឹងគេមានអ្នកគ្រប់គ្រងគេផ្សេង?

សុត ៖ បាទ!មានផ្សេងក្រៅពីកងទ័ព ។

ដានី ៖ អ្នកគ្រប់គ្រងខាងដឹកជញ្ជូនពីណាគេ?

សុត ៖ អ្នកដឹកជញ្ជូនហ្នឹងគេមានដំណាក់គេផ្សេង ដូចតាវ៉ាត តាប៉ុនខ្មោចតាប៉ុន ខ្លះនៅអូរតាឡោក ហ្នឹងគាត់ប្រធាននៅគ្រប់គ្រងពួកខ្ញុំនឹងម៉ែ៉ៗគេប្រធាន ។

ដានី ៖ ចុះកងទ័ពផ្សេង?

សុត ៖ កងទ័ពគេមានវរៈគេផ្សេង ។

ដានី ៖ ចុះខាងដឹកជញ្ជូន?

សុត ៖ ខាងដឹកជញ្ជូនគេបង្កើតសេដ្ឋកិច្ចគេនៅក្រោយ វាមានតាទូច ខ្មោចតាទូចជាអ្នកដឹកនាំខាងផ្នែកឃ្លាំង ដល់ពេលហ្នឹងមានហើយ មានខាងគ្រប់គ្រងផ្នែកខាងសេដ្ឋកិច្ចមានខ្មោចតាទូចតាជៀម ហ្នឹងឯងគាត់ជាអ្នកក្តាប់រួម ។

ដានី ៖ ចុះតាហុង?

សុត ៖ តាហុងគាត់ផ្នែកផ្សេងខ្ញុំមិនសូវដឹងទេ

ដានី ៖ ចុះម៉េចទៅការរស់នៅកាលហ្នឹង បន្ទាប់ពី៧៩-៨០ហូរហែរនៅក្នុងឆ្នាំ៨០ហ្នឹងជីវិត កាលហ្នឹងយ៉ាងម៉េចទៅ ពេលហ្នឹងយើងដូចថាពេលកងទ័ពវៀតណាមចូលម៉ោយើង វ៉ៃគ្នាយ៉ាងម៉េចហើយបន្ទាប់ពីវ៉ៃគ្នាយើងធ្វើអី ហើយការពារយ៉ាងម៉េចអីយ៉ាងម៉េច?

សុត ៖ យើងការពារដូចថាមានវិធានការទំនាក់ទំនងឡើងវិញ ការពារមូលដ្ឋាននឹងឯករាជ្យ ប្រទេសនីមួយៗគឺត្រូវតែមានអញ្ចឹងម៉ង មានដូចថាគេត្រៀមស្រាប់រួចហើយ ទី១អង្គរ ទី២គ្រាប់ទី៣មីន គេត្រូវតែដាក់ហើយ ដូច្នេះយើងដាក់ជាវៀងរាល់ថ្ងៃចែកកម្លាំងគ្នាការពារ អញ្ចឹងទៅចារូង អញ្ចឹងទៅតាមមូលដ្ឋានរៀងៗខ្លួនទៅ ។

ដានី ៖ ចារូងយើងធ្វើខ្លួនឯងទេ?

សុត ៖ ធ្វើខ្លួនឯងចែកកម្លាំងតាម បិទចារូងអ្នកណាយកទៅចាក់ៗទៅ ។

ដានី ៖ គេដាក់ធ្វើម៉េចទៅចារូងហ្នឹង?

សុត ៖ គេបំរូងធ្វើដូចយើងស្ទូងស្រូវអញ្ចឹង ចាក់ ។

ដានី ៖ ប៉ុន្តែគេធ្វើអត់ឲ្យយើងឃើញទេ ឧបមាថាពេលយើងដាក់យើងធ្វើម៉េចកុំឲ្យគេដើរជាន់?

សុត ៖ អានេះគេមានអាចារូងដេក ចារូងដើរ ចារូងអង្គុយមាន៣ផ្នែក ។

ដានី ៖ អញ្ចឹងអាចារូងគេដាក់ច្រើនដែរ?

សុត ៖ បាទ!ចំរូងកន្លែងណាក៏ដាក់ដែរ ដាក់ដើម្បីការពារដេកវាស្រួល សូម្បីតែដើរៗក៏ទាក់ដែរ ។

ដានី ៖ មីនខាងយើងដាក់ទាំងអស់ឬក៏ពីខាងក្នុងគេម៉ោដាក់ដែរ?

សុត ៖ ធម្មតាយើងនៅម៉ារយៈពីឆ្នាំ៧៩-៨៥ពេលហ្នឹងគឺរដ្ឋកម្ពុជា នឹងទាហានវៀតណាមបុក ទំលាយយើងអស់មួងរួចហើយ ពេលនោះហើយគឺថាបុកសម្អាតរលីងម៉ង ដូច្នេះហើយគេមកនៅកន្លែង នេះមួងអាហ្នឹងវាម៉ារយៈកាលទៀតណាស់ ពី៧៩មក៨៥នេះគឺ តំបន់ម៉ាឡៃនេះគឺតំបន់សំបូរទៅ ដោយមីនទាំងអស់ រហូតទៅទល់ប៉ៃលិនគឺបោសសំអាតដោយរដ្ឋកម្ពុជានឹងទាហានវៀតណាម មួងទៅហើយរយៈ៥ឆ្នាំ ពី៨៥-៨៩កាលហ្នឹងទាហានវៀតណាមមកនៅព្រំដែននេះ៥ឆ្នាំ ពី៨៥រហូតមកដល់៨៩ ។

ដានី ៖ បាទ!ចុះយើងទៅខាងដែរ?

សុត ៖ កាលហ្នឹងយើងខាងលើគេ ឬទៅនៅដីថៃម៉ាកន្លែងណាសិន ។

ដានី ៖ កន្លែងអីគេកាលហ្នឹងនៅហ្នឹង?

សុត ៖ បើយើងខាងខ្ញុំនេះ ខាងយើងសុខភាពនេះទៅកំពង់តាង៉ុកមួយចំនួន គេហៅថាសេះអេក ហ្នឹងប្រជាជនមួយចំនួន បានម៉ោពីឆ្នាំ៨០មកឆ្នាំ៨៥ប៉ុនបានប្រជាជនមកច្រើនដែរ រាប់ម៉ឺននាក់ដែរ ដែលគាត់ម៉ោអត់ឃ្លានម៉ោនៅជាមួយយើង ដល់អញ្ចឹងគាត់បានឲ្យទៅ នៅខាងកំពង់តាង៉ុកហ្នឹងបានឲ្យកាកបាទក្រហមគេចិញ្ចឹមទៅ ហើយខាងទាហានយោធា យើង ទាហានយើងខាងសុខភាពហ្នឹងគាត់ទៅសុំដីគេនៅភូមិជុំថង ទៅនៅហ្នឹង៥ឆ្នាំ ។

ដានី ៖ ពេលហ្នឹងយើងធ្វើសង្គ្រាមម៉េចទៅ?

សុត ៖ អត់ទេយើងទៅនៅហ្នឹង នៅប្រពន្ធកូនគេនៅសុខស្រួល មិននៅកណ្តាលវាលទេ ។

ដានី ៖ ចុះយើង?

សុត ៖ ធ្វើរបងព័ទ្ធជុំវិញទៅជំរុំគេ ហើយជំរុំៗយើងនៅឆ្ងាយពីប្រជាជនគេ ហើយព្រៃសុទ្ធដូចយើងនេះកាប់នៅកណ្តាលព្រៃ ពស់ប៉ិនៗត្បាល់ ។

ដានី ៖ ពស់អីគេហ្នឹង?

សុត ៖ ពស់វែកក៏មាន ពស់ប៉ិនៗកំភួនជើង ហើយយើងចេះតែនៅទៅ

ដានី ៖ បាទ!ចុះអើកង់ទ័ពនៅក្នុងហ្នឹងដែរឬក៏ចេញម៉ោ?

សុត ៖ កងទ័ពនៅក្នុងហ្នឹងទាំងអស់ ។

ដានី ៖ អត់មាននៅ?

សុត ៖ អត់មានទេ!គឺ៨៥អត់មាននៅក្នុងហ្នឹងមួយទេ បោសទាហានវៀតណាមហើយគឺរៀបចំសារជាថ្មីហើយ យើងមកដល់មានគេរៀបចំបន្ថែមទៀត គេដាក់ស្នេកស្កាសម៉ងតាំងពីរបងលួសរបង ព្រំដែនទៀតជាប្រពន្ធ័រឹងមាំម៉ង់ ។

ដានី ៖ យើងវិរអត់?

សុត ៖ បាទ!អត់ងាយទេ ដល់ពេលហ្នឹងមានឈ្លបម៉ោវិរម៉ោចូលម៉ោកន្លែងយើងបានត្រឹមមាត់ អូរទេ ។

ដានី ៖ ព្រោះគ្នាយើងច្រើន?

សុត ៖ ព្រោះអាពីនេះទៅថ្នល់ជាតិសុទ្ធតែព្រៃ ថ្នល់ជាតិថៃ ថៃអត់ហានធ្វើទេ កាលហ្នឹងថៃមិនទាន់មាន ថ្នល់កៅស៊ូនៅឡើយទេ មានថ្នល់កៅស៊ូដាច់ៗ ពីទៅសុទ្ធតែព្រៃទាំងអស់ យើងពួនបានក្បែរៗថ្នល់ជាតិហ្នឹង ។

ដានី ៖ ទៅដីថៃទៅ?

សុត ៖ យើងចល័តបាន ។

ដានី ៖ ចល័តក្នុងដីថៃ?

សុត ៖ ចល័តក្នុងដីថៃ ម៉ោដល់កន្លះខែមួយខែអីយើងក៏ឡើងទៅកន្លែងជំរុំយើងវិញ ។

ដានី ៖ ថៃអត់ថាអីទេ?

សុត ៖ អត់ទេ!ថៃគេមិនដឹកយើងទេ គ្រាន់តែយើងមានឡានដឹកខ្លួនយើង យើងម៉ោដឹកម៉ោដឹកទាហានយកម៉ោពីជំរុំម៉ោឃើញយប់អាគ្រោតម៉ងមកដល់ដាក់ម៉ោដើរដេកតាមផ្ទះ ។

ដានី ៖ ចុះពូៗរៀបការឆ្នាំណា?

សុត ៖ ខ្ញុំទឹមរៀបការដែរហ្នឹង រៀបឆ្នាំ៨២ហើយ ។

ដានី ៖ ឆ្នាំ៨២ពេលពូ?

សុត ៖ អត់ទេ!ដើម និយាយរួមចុងឆ្នាំ៨០ ខ្ញុំរៀបការតាំងពីយើងនៅមិនទាន់បែកមកម្ល៉េះ រៀបការហ្នឹងខ្ញុំរៀបការនៅនោះនៅមន្ទីរតាមួយ ។

ដានី ៖ បាទ!នៅណា?

សុត ៖ នៅមន្ទីរតាមួយយើងនៅខ្វាងវាប់នៅខាងភ្នំតូច ។

ដានី ៖ ដល់ហ្នឹងអ៊ើ!កាលហ្នឹងមីងគាត់ធ្វើអីបានជួបគាត់?

សុត ៖ គាត់ដឹកជញ្ជូនៗតាមដែលយើងស្នើរទៅ ។

ដានី ៖ កាលហ្នឹងរៀបការយ៉ាងម៉េចទៅ?

សុត ៖ ការចាប់ដៃគ្នាហ្នឹង កាលហ្នឹងខ្ញុំការឆ្នាំ៨០ ។

ដានី ៖ តាំពូហើយនឹងមីងប្អូនមានគូរគេអញ្ចឹងដែរ?

សុត ៖ មានៗចាស់ៗដូចគ្នា ស្រករៗគ្នា ។

ដានី ៖ កាលហ្នឹងពូអាយុប៉ុន្មានហើយ?

សុត ៖ ប្រហែលជា២៨-២៩ទៅ៣០

ដានី ៖ ដល់ពេលការហើយយើងនៅជុំគ្នាឬយ៉ាងម៉េច?

សុត ៖ គេឲ្យទៅផ្ទះទៅអីនៅជុំគ្នាម៉ារយៈសិន ទៅផ្ទះនៅហ្នឹងនៅកន្លែងកងហ្នឹង ។

ដានី ៖ ពេលយប់មកដេកផ្ទះ?

សុត ៖ ពេលយើងទៅប្រចាំការណ៍អីមួយខែឡើង ពេលយើងមកវិញមកដេកផ្ទះវិញម៉ោ ។

ដានី ៖ ពេលម៉ាខែគេឲ្យផ្ទះ ម៉ាខែគេឲ្យមកផ្ទះ ម៉ាខែគេឲ្យទៅប្រចាំការណ៍?

សុត ៖ ម៉ាខែ ពីរខែ បីខែអីទើបទៅម៉ាម្ដង សល់ពេលយើងនៅផ្ទះយើងប្រកបរបបអី ។

ដានី ៖ កាលហ្នឹងយើងធ្វើអី?

សុត ៖ ដាំស្រូវ ដាំត្រលាច ដាំពោតអីអញ្ចឹងទៅលក់ ។

ដានី ៖ អ៊ូរ!កាលហ្នឹងយើងធ្លាប់បានដាំដំណាំអីដែរ?

សុត ៖ បាទ!ដាំពោត ដាំសណ្ដែក ដាំស្រូវ យើងស៊ីរបបម៉េចនឹងគ្រប់ ហើយយើងដាំអញ្ចឹងទៅដល់ខែ យើងលក់បានលុយចាយខ្លះ បើអញ្ចឹងមានលុយណាចាយ ដុតធ្យូងៗរហូត ។

ដានី ៖ កាលហ្នឹងយើងដូចថាហូបចុកអីពីខាងណាគេម៉ោ?

សុត ៖ អត់ទេជំនួយពីខាងសុខភាពម៉ង តាំដល់ខែគេយកអង្ករបើកមកឲ្យ ។

ដានី ៖ យកតែអង្ករទេ? ចុះម្ហូបអី?

សុត ៖ ម្ហូបមានត្រីខកំប៉ុង មីអញ្ចឹងទៅ ហើយទឹកដោះគោទៅ ស្ករសយកមកដល់កន្លែងគឺអត់មានបាត់អីទេ ។

ដានី ៖ ហូបគ្រប់គ្រាន់ដែរឬអត់?

សុត ៖ គ្រប់គ្រាន់អត់មានឲ្យបាត់មួយខែទេ មានប្រហុក មានអំបិល ហើយប៊ិចេងទៀត ទាំងអស់ម៉ងម៉ាចប់ម៉ង ហើយយើងរកបានយើងសល់លុយ បានរបស់ម៉ោយើងយក ទៅលក់នៅជីថៃមួយថ្ងៃៗលក់ទិញៗយើង ។

ដានី ៖ អ៊ូ!ថៃកាលហ្នឹងទាក់ទង?

សុត ៖ អត់ទេ! ថៃកាលហ្នឹងស្រួលណាស់ អត់ដូចឥឡូវទេឥឡូវពិបាកដាផ កាលពីដើមស្រួល ។

ដានី ៖ ម៉េចអញ្ចឹង?

សុត ៖ឃើញៗពួកទ័ពយើង ពួកទ័ពព្រៃយើងគេហៅទ័ពខ្មែរក្រហមនោះណា កម្ពុជាប្រជាធិប គេឃ្យេ គេស្រឡាញ់គេថាពួកហ្នឹងវាត្រង់ធ្វើវាត្រង់ អត់ចេះលួចទេ ប៉ុនចោរតែដឹងថាលួច ហើយវាចាប់ តែចាប់បានហើយដឹងតែម៉ាទំរង់ហើយ វាគ្មានចោរផងមានតែចោរថៃ គ្នាវាហ្នឹង ។

ដានី ៖ ចុះពូទៅនៅកន្លែងជិតខ្លាងវាប់ហ្នឹងដល់ឆ្នាំណា?

សុត ៖ និយាយរួមពី៨០ដល់៨៥ ពេលបែកបានខ្ញុំចេញម៉ោចេញពីបន្ទាយហ្នឹងម៉ោ ពី៨០រហូត ដល់៨៥ម៉ង ។

ដានី ៖ បាទ! ហើយពី៨៥ហ្នឹងទៅ?

សុត ៖ ឆ្នាំ៨៥ខ្ញុំទៅកន្លែងយាយម៉ុក ។

ដានី ៖ ពី៨៥-៨៦យើងរើអស់ពីដីថៃហើយ?

សុត ៖ បាទ!ដីថៃនៅតាមព្រំដែន ម៉ាចំនួនចូលនៅក្នុងតាគង ។

ដានី ៖ អញ្ចឹងពេលហ្នឹងតាសុខ ភាព គាត់ក្តាប់នៅនេះទាំងអស់ម៉ង?

សុត ៖ បាទ!ទាំងអស់ហ្នឹងពីប៉ៃប៉ែតមកដល់យើងគីឡូលេខ៩នេះ ។

ដានី ៖ ហើយបន្ទាប់ពីគីឡូ៩រទៅ?

សុត ៖ គីឡូ៩នៅលើមេកន ។

ដានី ៖ ដឹងថាគាត់មកពីណា?

សុត ៖ មិនដឹងថាគាត់មកពីណាទេ ស្លាប់តាដនទៅ ឡើងតាកន ។

ដានី៖ អ្ហូ! តាដនគាត់ស្លាប់ឆ្នាំណា?

សុត ៖ មិនដឹងស្លាប់នៅឆ្នាំណាទេ ខ្ញុំចាំមិនច្បាស់ដូចជា៨៩អីក៏មិនដឹងទេ ។

ដានី ៖ គាត់ឈឺប្តក៏យ៉ាងម៉េច?

សុត ៖ ស្លាប់យើងទៅកាប់មីន ទៅកាប់មីនស្លាប់ ។

ដានី ៖ ចុះពេលតាដនស្លាប់ទៅឡើង?

សុត ៖ ឡើងតាកន ។

ដានី ៖ តាកនគាត់គ្រប់គ្រងទាំងៗតាភាព?

សុត ៖ តាកនគាត់គ្រប់គ្រងទាំងអស់ កាលវាគ្រប់គ្រងផ្នែកខុសគ្នា ដល់ពេលឆ្នាំការគ្រប់គ្រងខុសគ្នាម៉ង ។

ដានី ៖ ខុសគ្នាយ៉ាងម៉េច?

សុត ៖ ខុសគ្នាគេតាកន តាជនអីគេនៅខាងនិរតី គេនៅជុំវិញនិរតីគេជិតតាង៉ុកឯនោះ ជិតប្រជាជនធំ ហើយយើងនៅនេះនៅជិតតាជននេះខាងហិរញ្ញនេះ ហើយដល់អញ្ចឹងអាបញ្ហាការគ្រប់គ្រង អត់មានការប្រឫកប្របល់ទេ ខាងតាកន តាជនអីគេគ្រប់គ្រងម៉ាកន្លែងគ្នាគេទៅកន្លែង នេះគ្រប់គ្រងដោយសុខ ភាពតែឯងម៉ង អត់មានប្រឫកប្របល់ទេ ។

ដានី ៖ លែងមានតាជនអី?

សុត ៖ អត់ទេ!លែងមានតាជន តាកនទៀតហើយ តាជនផ្សេង តាភាពផ្សេងដឹងអញ្ចឹងអាពីហ្នឹងសិទ្ធ ប៉ុនគ្នា កងពលធំដូចគ្នា ៤៥០ហើយ ៣២០ គេដាក់៣២០ ដល់យើងនេះដាក់៤៥០

ដានី ៖ ហ្នឹងចាប់ពីរដ្ឋកម្ពុជាហើយនឹងវៀតណាមវ៉ៃបុកចូលម៉ោ?

សុត ៖ បាទ!ចាប់ពីហ្នឹងម៉ោ គឺយើងបែងចែកដាច់ដោយឡែកពីគ្នា កាលដែលមិនទាន់នៅវ៉ៃ បែកហ្នឹងវាដោយឡែកដែរ តែមិនទាន់ជាផ្លូវការ ខាងយើងនេះស្រុកម៉ាឡៃនេះ គេហៅតំបន់១០២ គ្រប់គ្រងដោយសុភាពផ្ទាល់ ហើយដល់ពេលខាង តាកននោះជា ផ្លូវការសំងាត់របស់គេ យើងមិនដឹងច្បាស់ទេគេដាក់គេហៅមន្ទីរ៨៤ យើងនេះ១០២ គេនោះ៨៤ ហើយគេ៨៤គ្រប់គ្រងដោយតាកនផ្ទាល់ មាន សុន សេនអញ្ចឹងទៅណាស៎ មិនដឹងថា សុន សេន មុខម៉េចទេស៎ ខ្ញុំមិនដែលឃើញមុខទេ លឺតែ សុន សេន តែអត់ដែលស្គាល់គាត់ទេ ។

ដានី ៖ ចុះខាងនេះ?

សុត ៖ យើងនេះគឺគ្រប់គ្រងដោយ តាសុខភាពផ្ទាល់ គ្រប់ផ្នែកទាំងអស់លើគាត់ ហើយគេចាត់ចែងណាគេអត់ដឹងទេណា៎ ព្រោះគាត់យោធានៅកាន់បន្ទាយធំនោះ ។

ដានី ៖ អញ្ចឹងរហូតដល់ឆ្នាំ៨៩បានគេចូលមកនៅវិញ?

សុត ៖ បាទ!ដល់ឆ្នាំ៨៩បានយើងវ៉ៃផ្តាច់ជាក្រុមៗ ។

ដានី ៖ កាលហ្នឹងយ៉ាងម៉េចបានគេវ៉ៃផ្តាច់បាន?

សុត ៖ ព្រោះកងទ័ពទាំងអស់ធំទាំងអស់ ចាប់ពីតាគងម៉ោរហូតមកទល់នឹងក្បាលបារាំង តែកន្លែងពីមុខតូចតាចសម្រាប់វ៉ៃមិនឲ្យធ្លាក់មកពីខាងក្រោយបាន គ្រាន់តែធ្លាក់ទៅ បាញ់បុកនៅវ៉ូងនឹងទៅ បាញ់បុកពីបារាំងទៅណា៎ បាញ់បុកពីដីថៃបុកពីនេះទៅកុំឲ្យឯងទៅខាងក្នុង វ៉ៃពីក្នុងផ្តាច់គេថា ផ្តាច់ផ្លូវសេដ្ឋកិច្ច ឡានម៉ោមួយ រត់ចោលៗកាំភ្លើង អញ្ចឹងយើងចូលមកវិញ

ម៉ោចូលឆ្នាំ៨៩ ក្បែរឆ្នាំ៩០ហ្នឹង ចូលម៉ោកន្លែងទីតាំងវាសុទ្ធតែមីនទាំងអស់កន្លែងណាក៏មីនដែរ តាមនេះក៏មីនដែរ ។

ដានី ៖ ធ្វើម៉េចទៅអញ្ចឹង?

សុត ៖ រាវខ្លួនឯង ។

ដានី ៖ ច្រើនទេពូ?

សុត ៖ ច្រើនជាអតិបរមា របួសនឹងស្លាប់ច្រើនណាស់ អាពិការៗក៏ច្រើនដែរនៅតាមភូមិ ។

ដានី ៖ អ្ហូ!ដោយសារមីនហ្នឹង?

សុត ៖ ដោយសារមីន រាវមីនដោយខ្លួនឯង គ្រោះថ្នាក់ដោយខ្លួនឯងទៀត ស្លាប់ក៏ស្លាប់ទៅ មេម៉ាយប្រពន្ធទៅ ខ្លះក៏នៅរស់ពិការទៅ ។

ដានី ៖ បាទ!ចុះចាប់ពី៨៩ទៅចូលម៉ោមកវិញ យ៉ាងម៉េចទៅការរើជាមួយអ្នកខាងក្នុងជាមួយកងទ័ពវៀតណាម?

សុត ៖ ដល់ហ្នឹងវាមានកិចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល អ្នកខ្លះបានស្តាប់ អ្នកណាមានវិទ្យុ បានស្តាប់ អ្នកណាមិនមានវិទ្យុយើងមិនបាន ស្តាប់វិទ្យុចាប់ផ្តើមសម្របសម្រួល គ្នាបណ្តោយសម្របសម្រួលដោយរាជរដ្ឋាភិបាលជាមួយនឹងកងទ័ពត្រីភាគីហ្នឹង អញ្ចឹង យើងកាត់បន្ថយការវាយប្រហារគ្នា យើងទៅមុខក៏សូវរើគ្នាដែរអត់សូវរើគ្នាទេ រហូតទល់៩២ទើបបានយើងដឹងថា ការព្រមព្រៀងបានម៉ាចំនួនធំ តែយើងចេញចូលអត់បានទេ ចេញចូលបានតែមេធំៗ យើង តូចតាចចេញចូលសេរីមិនបានទេរហូតដល់៩៣ ដល់៩៣ហ្នឹងទើបមានការបោះឆ្នោតទៅ មាន ការបោះឆ្នោតយើងនេះក៏មិនបាកបោះឆ្នោតដែរយើងចង់បោះឆ្នោតប៉ុន្តែគេមិនឲ្យយើង បោះឆ្នោត ។

ដានី ៖ ម៉េចអញ្ចឹង?

សុត ៖ គេឲ្យប្រជាជនយើងទៅបោះនៅប៉ៃប៉ែត ។

ដានី ៖ បានទៅបោះទេ?

សុត ៖ ប្រជាជនគេទៅបោះ អ្នកណានៅជាប់សម្តេច ពួកយើងនេះមិនបានទេ តែប្រជាជននៅ ជំរុំតាអេក ទៅបោះទាំងអស់ កាលហ្នឹងជំរុំគាត់យើងយកពីដីខេត្តមកយកដាក់នៅ កន្លែងយាយអកហ្នឹង ដូច្នេះអ្នកដែលនៅកន្លែងយាយអកត្រូវទៅបោះឆ្នោតទាំងអស់ ព្រោះអាហ្នឹងជាប្រជាជនខ្មែរក្រហមទៅបោះទាំងអស់គ្នា អត់តែទាហានទេមិនបានទៅបោះព្រោះខ្លាចគេចាប់គេចងទៀត ។

ដានី ៈ ធ្វើម៉េចកាលហ្នឹងបានខាងខ្មែរក្រហមទៅដកខ្លួនចូលរួម?

សុត ៈ អាហ្នឹងមិនដឹងម៉េចកិច្ចការផែនយោបាយរបស់គេខាងលើ គេធ្វើម៉េចយើងមិនដឹងដែរ គេអត់បានប្រាប់យើងច្បាស់លាស់ទេ គ្រាន់តែដឹងថាបើមេទៅណាគឺកូនទៅហ្នឹងហើយ ព្រោះយើងដឹងតែប៉ុណ្ណឹងឯង ដល់អញ្ចឹងមេអត់បោះឆ្នោត ក៏ឲ្យប្រជាជនយើងបោះឆ្នោត បងប្អូនម៉ែឪយើងណាស់ឲ្យទៅបោះ យើងទាហានចាំបាច់មិនត្រូវទៅបោះបានទេ ។

ដានី ៈ អញ្ចឹងបន្ទាប់ពី៨៩ម៉ោយើងនៅនេះលែងដូចជាធូរស្រាលហើយលែង?

សុត ៈ បាទ! លែងអីហើយតាំងពី៨៩ម៉ោយើងធូរស្រាលពីការប្រយុទ្ធគ្នា ។

ដានី ៈ ប៉ុន្តែផលវិបាកមាន?

សុត ៈ ផលវិបាកមាន ក៏ប៉ុន្តែផលវិបាកមួយទៀតគឺពេលហ្នឹងយោធាយើង១០២ កងពល សុខភាពមិនសប្បាយចិត្តនឹងអាពួក៣២០ ឆ្នាំ៨៩អត់សប្បាយចិត្តនឹងពួកហ្នឹង ។

ដានី ៈ ម៉េចអញ្ចឹង?

សុត ៈ ពេលបោះឆ្នោត ពួកហ្នឹងវាធ្វើអំពើមិនល្អ វាធ្វើខុសពីឆន្ទះដែលយើងនិយាយគ្នាកិច្ចព្រមព្រៀង ជាមួយនឹងរាជរដ្ឋាភិបាលយើងអត់សប្បាយចិត្តនឹងគ្នា ដូច្នេះអាភាគីពីរ ហ្នឹងគឺអត់យោធា ៣២០នឹង២៨ហ្នឹងអត់ត្រូវគ្នាទៀត យើងថាយើងឈប់ប្រយុទ្ធគ្នា ព្រោះខ្មែរនឹងខ្មែរត្រូវ ស្លាប់គ្នាឯង គេនឹងគេថាគេត្រូវតែប្រយុទ្ធទាល់តែរួច យើងថាត្រូវតែចូលសម្របជាមួយរដ្ឋា ភិបាល គេថាមិនសម្របទេ ដឹងតែមានការឈ្លោះ ដូច្នេះពីរហ្នឹងអត់ត្រូវគ្នាទេ ម៉ោទល់តែមាន ការបែកឆែរ ដល់ពេលអញ្ចឹងការផ្សព្វផ្សាយសំងាត់ទូទាំងយោធាទាំងអស់ វាដឹងថា មាំខ្សែនេះ គឺត្រូវតែសម្របសម្រួលជាមួយរដ្ឋាភិបាលម៉ង់ អត់ត្រូវគ្នាជាមួយពួកប្រឆាំងទេ បានយើង កាត់បន្ថយធ្វើបានកាន់តែចាប់ពី៩៣ម៉ោចូល៩៨ ចាប់ផ្តើមប្រយុទ្ធគ្នាម៉ង់ យោធាហើយនឹង ខ្មែរក្រហមៗដូចគ្នានោះណាអត់ត្រូវគ្នាទេ ខាងនោះគេថាគ្មានអាណាបជាមួយរដ្ឋកម្ពុជាទេយើង យើងថាយើងកាន់ជើងតែខ្មែរ យើងក៏ខ្មែរដែរ ផ្លូវវៀតណាមគេដកអស់ហើយ តើយើងទៅធ្វើអីទៀត ។

ដានី ៈ បាទ!

សុត ៈ ដល់នេះវាថាយើងអាយ៉ងហ៊ុន សែន អាយ៉ងរដ្ឋកម្ពុជា ហើយយើងថាពួកឯងពួក អាកម្មុនីស្តសម្លាប់ប្រជាជន គេកម្លាំងច្រើនជាងយើង គេកម្លាំងជាង២ម៉ឺន យើងកម្លាំងត្រឹមតែ១ម៉ឺនជាង ទេ ហ្នឹងចាប់ពី៩៨ម៉ោទេណាស់ រហូតដល់៩៨-៩៥ចាប់ផ្តើមៗ

យើងខកចិត្តកាន់តែខ្លាំងជា មួយពួកវាទៀត ជាមួយពួកខាងហ្នឹងទៀត អាគ្នាយើងហ្នឹង អាស់ ប៉ុន្តែយើងខកខានមែនតែចិត្ត នៅជជែកៗជាមួយគ្នា ជជែកជាមួយគ្នាអាអ្នកដែល យើងស្គាល់គ្នានោះណាស់ ជជែកគ្នាឲ្យយល់ អាបញ្ហាហេតុផលហ្នឹង កុំបញ្ចេញអាវុធ កុំបញ្ចេញគ្រាប់យកទៅបាញ់គ្នា វានាំឲ្យប៉ះពាល់ដល់ គ្នាឯង វាខាតបង់តែទ្រព្យយើងទេ ។

ដានី : បាទ!

សុត : យើងចេះតែណែនាំទៅ អ្នកខ្លះគេតាមយើងទៅ ភាគច្រើនគេតាមយើង គេថាហ៊ី!មានហេតុផល គេបោះឆ្នោតម្ដងរួចហើយ ឯងមិនទាន់បានបោះឆ្នោតផងហើយ អាឯងមិនទាន់បានបោះឆ្នោតផងរករឿងទៀត ដល់អញ្ចឹងអាមួយចំនួនគេចង់បោះឆ្នោត ៩៨ដែរ អាណត្តិទី២ អាណត្តិ ទី១រួចហើយកាល៩៨ ដល់អញ្ចឹងវាឈរមុខដាក់គ្នា កាល៩៦ថ្ងៃ១៥ហ្នឹង ខ្លាំងជាងគេម៉ង ឈរមុខដាក់គ្នាខ្លាំងមួយខែ អត់អាចទាក់ទង គ្នាបានដាច់ខាត កាត់ផ្ដាច់ព្រំប្រទល់បឹងប៉េងហ្នឹង អត់ឲ្យចូលម៉ាឡៃ តាចូលម៉ៅរឿងម៉ង យើងទៅក៏មិនបានគេម៉ោក៏មិនបាន តែបើម៉ោសុំគេឲ្យ ម៉ោ តែបើយើងទៅសុំគេទៅ ក៏គេអត់ឲ្យទៅដែរ គេស្អប់យើងម៉ង តែយើងក៏មិនចង់ទៅដែរ តែយើងចង់ទាញគ្នាយើង ទាញបងប្អូនយើងដែលនៅនោះ ឲ្យដឹងហេតុផល ដល់នេះគេចាប់ ផ្ដើមប្រើអាវុធៗ យកមកគំរាមយើង ហើយយើងក៏មានអាវុធដែរ អាវុធម៉ោនេះទាំងអស់ មុនដំបូង យកមកទុកទប់ទល់នឹងយើង ទប់មិនបានគេរើ គេរើអាវុធទាំងឡាយដែលនៅទីនេះ យើងយកទាំងអស់ អាមុនមួយខែវាលួចប្រមូលតាំងពីរថក្រោះ រថយន្តភ្លើងអា១០៥ អា១២២វាយកបានទាំងអស់ ដល់អញ្ចឹងយើងមិនបានរើគ្នាទេ គ្រាន់តែនិយាយគ្នាទៅ យើងឯកភាពគ្នាទៅ ក៏យើងធ្វើសមាហរណកម្មទៅ ធ្វើសមាហរណកម្មបានតែពយក យើងទេ បានតែម៉ាឡៃមុនដំបូង ឆ្នាំ៩៦បានតែម៉ាឡៃ នឹងប៉ៃលិនប៉ុណ្ណោះទេ សំពៅលូន នេះអត់ទទួល សមាហរណកម្មទេណាស់ ពេលយើងធ្វើសមាហរណកម្មយើងទៅប្រយុទ្ធ លើកទ័ពទៅរើអស់ ម៉ង ទាល់តែមេៗរត់អស់ម៉ង បានកូនធ្វើសមាហរណកម្ម ដ៏ សុន សេនរត់ទាល់តែមេកងរត់ ហើយចូលប្រយុទ្ធមានឯណា មានតែសុន សេន មានតែ មេកងហ្នឹងឯង អាកូនទាហានឃើញមេរត់ក៏រត់ដែរទៅ អានេះជាទិសដៅដែលយើង ផ្សះផ្សារជាតិ ។

ដានី : កាលហ្នឹងដូចថានៅស្រុក ភូមិម៉ាឡៃពេលដែលយើងចូលម៉ោភ្លាមហ្នឹង យើងចាប់ផ្ដើម កសាងមានអីគេខ្លះ តាំងពី៨៩ម៉ោ?

សុត ៖ តាំងពី៨៩ម៉ោយើងរៀបទៅតាមមន្ទីរៗដូចថា ពួកខ្ញុំម៉ោនេះគេរៀបជាក្រុមៗ ម៉ាក្រុម មាន ១០នាក់ ហើយតាមកងអញ្ចឹងមានប៉ុន្មានគ្រួសាររៀបជាគ្រួសារទៅ ធ្វើជាផ្ទះនៅ វាទព្រៃ ឡើងវាល ។

ដានី ៖ ចុះកាលហ្នឹងមានបែកចែកដូចភូមិ ឃុំ អីឬអត់?

សុត ៖ អ៊ើ!កាលហ្នឹងមិនទាន់បែងចែកភូមិនៅឡើយទេ បាទឥឡូវយើងនៅកាលឆ្នាំ៨៤ នៅជាមន្ទីរគេហៅថា មន្ទីរដឹកជញ្ជូន មន្ទីរក្នុង ឬក៏មន្ទីរខាងសុខាភិបាលអញ្ចឹង ក្រុមមន្ទីរពេទ្យអញ្ចឹងទៅ ក្រុម១១១ ១០៧អញ្ចឹងទៅ ។

ដានី ៖ ចុះពេលហ្នឹងយើងចាប់ផ្ដើមធ្វើស្រែ ធ្វើចំការខ្លួនឯងឬក៏នៅតែមានជំនួយ?

សុត ៖ បាទ!ដល់ហ្នឹងយើងម៉ោចាប់ដីរៀងខ្លួន ដល់ចូលមកឆ្នាំ៨០-៩០យើងមកចាប់ដី តាមអន្ក ភាពអ្នកខ្លះចាប់ដីបានច្រើន ខ្លះបានតិចទៅវាពិបាកគ្នាធ្វើ បានម្នាក់បន្តិចៗ ចាប់ធ្វើកាប់ឆ្ការដាំពោត លក់ឲ្យថៃទៅ ហើយអន្ករយើងទិញគេឲ្យខ្លះម៉ោ ហូបទៅ ទៅស្រែផលធ្វើចំការផលអត់បាន ច្រើនទេម្នាក់២រ៉ៃ ៣រ៉ៃ ៥រ៉ៃ ១០រ៉ៃអស់ហើយ ។

ដានី ៖ កាលហ្នឹងយើងធ្វើស្រែ ធ្វើចំការយើងកាប់ឈើកាប់ព្រៃឬយ៉ាងម៉េច ឬឈើហ្នឹងគេកាប់ផ្សេង?

សុត ៖ អត់ទេ!យើងកាប់ខ្លួនយើង ដូចថាម៉ោជាប្រចាំការអញ្ចឹងទៅ យើងបេះតែរានៗតិចទៅ ។

ដានី ៖ ចុះដល់ពេលធំៗ?

សុត ៖ ពេលធំៗអាហ្នឹង ដល់ពេលមែនទែនវាអត់មានលំបាកអីទេ ជួនកាលយើងដុតអាតូចៗក៏វាដួល ដែរ ដួលក្រាំងទៅម៉ង អាណាធំពេកទុកសិនទៅ ដូចយើងថាជនជាតិអញ្ចឹងអាណាធំវានៅទៅ អាណាតូចវាអស់ទៅ ។

ដានី ៖ ចុះអាធំៗគេយកទៅណាអស់ទៅឥឡូវ?

សុត ៖ គេកាប់អស់ គេកាប់លក់គេកាប់អីអស់ហើយ យកទៅខាងថៃ ។

ដានី ៖ តាំងពីឆ្នាំ៨៩ហ្នឹងម៉ោឬក៏តាំងពីណាមក?

សុត ៖ ទេស៎!តាំងពីឆ្នាំ៩០ម៉ោរហូតទល់មកឆ្នាំ៩៣នេះ ចាប់ផ្ដើមទន្ទ្រានព្រៃឈើ អស់ហើយ អាធំៗនេះ ប៉ុនយើងកូនចៅគេម៉េចហាន យើងកាប់តែអាណាមែកៗតូចៗទៅ ដូច្នេះ ឈើកាលឆ្នាំ៩០រហូតដល់៩៣ហ្នឹងឈើនៅច្រើនទេ ដល់ពេលឆ្នាំ៩៦នេះពេញខ្វាំងម៉ង ។

ដានី ៖ ៩៦ពេលសមាហរណកម្មហើយនេះ?

សុត ៖ បាទ!៩៦ពេលសមារណកម្មហើយនេះគឺពេញទំហឹងម៉ង ។

ដានី ៖ ខាងណាជាអ្នកនេះ?

សុត ៖ អេ៎!អាហ្នឹងខាងយើងអ្នកកាប់ បើយើងមិនកាប់បានអីធ្វើចំការ អញ្ចឹងបើមិនធ្វើបាន កន្លែងអីរស់នៅ ។

ដានី ៖ អញ្ចឹងចាប់ផ្ដើមពីសមាហរណកម្មហើយ យើងប្រែប្រួលម៉េន?

សុត ៖ ប្រែប្រួល ។

ដានី ៖ ប្រែប្រួលយ៉ាងម៉េចទៅ?

សុត ៖ ប្រែប្រួលពីអត់មានដី មានដី យើងចាប់ដីរៀងខ្លួន ។

ដានី ៖ អាហ្នឹងចាប់ហ្នឹងយើងចាប់ទៅតាមលទ្ធភាពរបស់យើង អ្នកណាចាប់បានច្រើនបានច្រើន អ្នកណាចាប់បានតិចអាហ្នឹងបានតិចអេស៎?

សុត ៖ បាទ!តាមលទ្ធភាពរបស់យើង ព្រោះអាហ្នឹងមេគេប្រកាសទេ មេប្រកាសថាឥឡូវយើងធ្វើសមាហរណកម្មយើងត្រូវមានដី ឥឡូវចាប់តាមអន្តភាពទៅចែកគ្នាទៅ កុំឲ្យឈ្លោះ ប្រកែកគ្នាចាប់ទៅ ហើយយើងទៅចាប់ទៅអាណាខ្ជិលក៏បានតិចទៅ អាណាខស្សាហ៍ ក៏បានច្រើនទៅ អាណាដែលមិនសូវហានក៏បានតិចដែលទៅ អាណាដែលមេៗគេយកធំ អញ្ចឹងទៅដល់អញ្ចឹងអាមេ ៗគេបានច្រើនបានធំ អាកូនៗបានតូចបានតិចអញ្ចឹងទៅ ។

ដានី ៖ បាទ!មេៗគេមានកូនចៅច្រើន?

សុត ៖ អាឯងម្នាក់ឯងគ្មានកូន ។

ដានី ៖ ចុះឈើធំៗគេចាប់ផ្ដើម?

សុត ៖ ឈើធំៗពេលហ្នឹងក៏ចាប់ផ្ដើមហាលបណ្ដើរៗហើយកាប់បណ្ដើរៗទៅ កាប់ហើយអារជា កង់ៗទៅដើម្បីយកចេញមកធ្វើផង ម្យ៉ាងដោះស្រាយជីវភាពខ្លួនឯងផងទៅ យក លក់ដូរខ្លះទៅ ។

ដានី ៖ យើងចាប់ផ្ដើមពីហ្នឹងម៉ោ ចាប់ផ្ដើមពី៩៣សមាហរណកម្មម៉ោ បានន័យថា យើងចែក ជាភូមិជាស្រុក?

សុត ៖ បាទ!ចាប់តាំងពីសមាហរណកម្មម៉ោយើងចែកភូមិ ចាប់ធ្វើសមាហរណកម្មបានប្រហែលជាកន្លះ ទៅមួយខែយើងចាប់ផ្ដើមរើកភូមិ យើងរើកភូមិដោយខ្លួនឯងតែម្ដង ដោយ សុខភាពជាអ្នក ប្រកាសជាផ្លូវការឲ្យរៀបចំទៅតាមទីកន្លែង ភូមិណាៗអីប្រកាសជាផ្លូវការរួចជាស្រេចម៉េង គេ ហៅមេៗដូចខ្ញុំនេះមានមេ ខ្សែ សំដង អញ្ចឹងទៅនោះគេមានមេតាយិនអញ្ចឹងទៅណា មាន មេតាមពេទ្យ ហើយគេចែកថាភូមិណាៗគេដាក់ភូមិក្បាលស្ពានអញ្ចឹងទៅ គេចាប់ផ្ដើមដាក់ លេខឈ្មោះភូមិ ។

ដានី ៖ ពីឆ្នាំ៩៦ម៉ោ?

សុត ៖ បាទ!ពីឆ្នាំ៩៦ម៉ោ ទៅជាភូមិក្បាលស្ពាន ភូមិអន្លង់វិល ភូមិគ្គុល ភូមិអីស្រេចម៉ង ហើយចាប់ ផ្ដើមរហូតទាល់តែយើង ឆ្នាំ៩៦ហ្នឹងមិនទាន់ជាផ្លូវការទៀត ត្រឹមតែអនុក្រឹតទេ ធ្វើដំណើរទៅ ហើយមិនទាន់ចុះព្រះរាជក្រឹត្យឲ្យយើងទទួលស្គាល់ពេញទីនៅឡើយ ត្រឹមតែ អនុក្រឹត្យនៅឡើយ ហ្នឹង ទទួលស្គាល់ជាផ្លូវការមិនទាន់បានទេមុនដំបូង ។

ដានី ៖ បាទ!គេហៅស្រុកម៉ាឡៃអញ្ចឹងម៉ង?

សុត ៖ ហើយយើងសុំធ្វើស្រុកម៉ាឡៃហ្នឹងដើម្បីឲ្យទៅជាច្បាប់ម៉ង យើងដាក់ស្រេចម៉ងពេលរៀប ហើយអញ្ចឹងគេប្រាប់អ្នកភូមិរួចជាស្រេចម៉ងថា អ្នកណានៅភូមិណាៗ ហើយមន្ទីរពេទ្យ នៅភូមិលើ ហើយបង្កើតស្រុកមួយឈ្មោះ ស្រុកម៉ាឡៃ ។

ដានី ៖ គេចាត់តាំងម៉េចទៅដូចថាជាភូមិ ជាឃុំ ជាស្រុកហ្នឹងគេមានអ្នករៀបចំចាត់តាំងដូច រឿងមេភូមិ មេឃុំ មេស្រុកយ៉ាងណាទៅ?

សុត ៖ បាទ!ពេលនោះអ្នកណាដែលធ្លាប់នៅមន្ទីរស្រុក គេនៅស្រុកដដែលឈ្មោះ ឈឹម មន្នី គាត់ជា អ្នកចាត់ចែង ជាអភិបាលចាត់ចែងភូមិ ឃុំ អ្នកដំបូងគេគឺ ឈឹម មន្នី អ្នកបង្កើតភូមិ ឃុំ ដំបូងគេគឺឈឹម មន្នី ហើយ ។

ដានី ៖ ចុះកាលពីមុនធ្វើសមាហរណកម្មគាត់ធ្វើអី?

សុត ៖ គាត់កងពល ក្រោមសុខ ភាព ។

ដានី ៖ ពេល ឈឹម មន្នី គាត់មកធ្វើគណៈស្រុកបានរយៈពេលប៉ុន្មាន?

សុត ៖ បានយូរដែរ ប្រហែលជាមើលតាំងពី៩៦ម៉ោរហូតមកទល់៩៦-៩៧-៩៨-៩៩-២០០០ ទឹមចូលទេ ។

ដានី ៖ ចុះបន្ទាប់ពី ឈឹម មន្នីម៉ោ?

សុត ៖ បន្ទាប់ពីនេះអត់មានទេ មានតែមួយហ្នឹង ឈឹម មន្នី កាន់កាប់បានប្រមាណជិត១០ឆ្នាំ ពី៩៦ មកដល់ឆ្នាំ២០០០ប៉ុន្មានទេ ។

ដានី ៖ ហើយចូលមកក្រោយម៉ោបាន?

សុត ៖ បាន ទេព ប៉ូណាល់ ។

ដានី ៖ ចុះកាលពីមុន ណាល់គាត់ធ្វើអី?

សុត ៖ តាណាល់អត់ដឹងដែរ ខ្ញុំមិនដែលស្គាល់ដែរ ពេលធ្វើសមាហរណកម្មហើយបានប្រហែលជិត មួយឆ្នាំទើបឃើញម៉ោ ។

ដានី ៈ គាត់ធ្វើអីទៅពេលម៉ោ?

សុគ ៈ ម៉ោមានធ្វើអី គាត់ជាប្រជាជនធម្មតា នៅភូមិក្បាលស្ពាន

ដានី ៈ ហើយម៉េចបានគាត់ឡើងដល់?

សុគ ៈ យើងមិនដឹងដែលអាបញ្ហានេះ កិច្ចការគេ គេលាក់អីយើងមិនដឹងទេ បើចំពោះខ្ញុំៗមិនដែលស្គាល់គាណាល់ ទើបឃើញកាលធ្វើសមាហរណកម្មហើយ មួយឆ្នាំហើយទើបឃើញម៉ោ ។

ដានី ៈ ចុះពីមុនគាត់អត់ដែលនៅហ្នឹងទេ?

សុគ ៈ អត់ទេ!អត់ដែលទេ គាត់មិនដឹង ព្រោះយើងនៅឯព្រៃនោះយើងមិនដឹងគេអ្នកធំដែល ។

ដានី ៈ តាមពូស្គាល់តាំងឆ្នាំ៩៦ម៉ោ មានការប្រែប្រួលអីយ៉ាំងម៉េចខ្លះស្រុកភូមិម៉ាឡៃយើងដំបូងដូចថា ការរៀបចំភូមិ ឃុំអី ប្រជាជនអីយ៉ាំងម៉េច ការប្រកបរបរអីដូចមានការប្រែប្រួលដូចម្ដេច?

សុគ ៈ បើនិយាយពីការប្រែប្រួលវិញគឺថា កាលពីមុនវាព្រៃស្តុកស្ដេស មកមានផ្លូវមានថ្នល់ខ្វាត់ខ្វែង វា គេហៅថាមោទណភាពមួយចំពោះយើង យើងម៉ោនេះចោលភូមិចោលស្រុកហើយម៉ោ នៅមានទឹកមានដីចោលស្រែចំការរបស់យើង ខ្ញុំនេះមានការតស៊ូតាំងពីម្ដាយឪពុកស្លាប់ពីភូមិ កំណើតមកនេះដូចជាភូមិកំណើតទីពីរហើយណស៎ ដែលយើងបង្កើតដោយខ្លួនឯង ក្នុងការ បង្កើតភូមិក៏យើងចូលរួមបង្កើតដោយខ្លួនឯង គេឲ្យយើងធ្វើនៅគ្រប់គ្រងនៅហើយ គេឲ្យយើង គូសដែនទី ដូច្នេះអាបញ្ញត្តិនេះវាដូចថាយើងជាអ្នកគ្រប់គ្រងនៅក្នុងភូមិនេះតាំងពីដើមម៉ោ ព្រោះយើងជាអ្នកគ្រប់គ្រង ហើយយើងប្ដេជ្ញាថានឹងធ្វើភូមិនេះឲ្យទៅជាភូមិមួយដូចថាឲ្យជាតិ ទទួលស្គាល់ជាផ្លូវការរហូតមិនឲ្យបាត់បង់ទេ ។

ដានី ៈ ពូធ្វើមេឃុំតាំងពីពេលណាម៉ោ?

សុគ ៈ តាំងពីហ្នឹងម៉ោ តាំងពី៩៨ម៉ោគឺតាណីគេឲ្យខ្ញុំធ្វើ តាណីកាលមុនដល់នេះ នេះដីតាណីដែរ ។

ដានី ៈ ចុះពូដូចថាកាលពូចេញពី៩៩ម៉ោពូកាប់ដីកាប់អីធ្វើស្រែចំការ ដូចថាជីវភាពខុសពីមុនយ៉ាំងម៉េច ដែរ ពីមុនសមាហរណកម្ម ហើយនឹងក្រោយម៉ោតើជីវភាពខុសគ្នាយ៉ាំងម៉េចដែរ?

សុគ ៈ និយាយពីមុនម៉ោយើងស៊ីរបបៗដែលគេឲ្យយើងដោយកំណត់ ក្មេងៗគេអត់មានសិទ្ធទេ អត់មានប្រើប្រាស់ពីរបបរបស់យើង ។

ដានី ៈ បើគិតទៅជីវភាព បើប្រៀបធៀបកាលពីមុនហើយនឹងឥឡូវយ៉ាំម៉េចដែក មួយណាប្រសើរជាង ធូរធាជាង?

សុត ៈ គ្មានអីប្រសើរជាងរបបយើងឥឡូវនោះ គេហៅថារបបកំណត់ យើងគ្មានសិទ្ធអីនឹង ចាត់ចែងចែងខ្លួនឯងបានទេ ដីឥឡូវយើងចាត់ចែងគ្រប់បែបយ៉ាងដោយខ្លួនយើងម៉ង គ្មានអ្នកណាគេជ្រៀតជ្រែកយើងបានទេ ធ្វើម៉េចឲ្យតែស្របច្បាប់ ដល់ស្របតាមរដ្ឋធម្ម នុញ្ញយើងក៏មានតំណាងជ្រើសរើសទៅតាមហ្នឹងទៅ ។

ដានី ៈ មួយទៀតខ្ញុំចាប់អារម្មណ៍មួយទៀតដូចថា ផ្ទះសម្បែងអីធ្វើផ្ទះស្រដៀងថៃ អត់ដូចផ្ទះយើងនៅខាងក្នុងទេ?

សុត ៈ អានេះបើនិយាយទៅម៉ូដនេះគេធ្វើតាមម៉ូដថ្មី ដោយសារយើងតាមគ្នា យើងស្រលាញ់អញ្ចឹងដង?

ដានី ៈ អាហ្នឹងវាមានប្រយោជន៍ម៉េចខ្លះយើងធ្វើផ្ទះតាមម៉ូដថៃ?

សុត ៈ អានេះវាប៉ុន្មានម៉ែត្រធ្វើទាំងអស់ អត់កាប់ទេ អានេះយើងមើលៗពិទិដ្ឋភាពជាក់ស្តែង ។

ដានី ៈ យើងមើលទៅឃើញផ្ទះវាស្រដៀងគ្នាតាមម៉ូដថៃ ខ្មែរយើងនៅក្នុង ចុះនៅនេះភាគច្រើននិយមខាងថៃ ដូចថាសម្លៀកបំពាក់ របស់របរប្រើប្រាស់ ហូបចុក យើងប្រើរបស់ថៃទាំងអស់ឬក៏យ៉ាងម៉េច?

សុត ៈ អត់ទេ!ទំនៀមទំលាប់របស់ខ្មែរយើងអំពីអត្តចរិក របស់ប្រជាជនយើងមិនស្រលាញ់ទេខាងស៊ីវីល័យអត់ស្រលាញ់សោះ ហើយមើលការស្លៀកពាក់សព្វថ្ងៃនេះក៏អញ្ចឹងដែរ មានមួយៗទេ ១០នាក់មាន១ទេដែលចូលចិត្ត ដូច្នេះ១០០នាក់មាន២ទេដែលចូលចិត្តស៊ីវីល័យក្រៅពី ហ្នឹងគេចូលចិត្តសម័យខ្មែរ ។

ដានី ៈ ចុះយើងរាល់ថ្ងៃនៅរកស៊ីអីទាក់ទងជាមួយថៃយ៉ាងម៉េចដែរ?

សុត ៈ រឿងរកស៊ីបើយើងនិយាយលើច្បាប់វិញ គឺយើងមិនដែលរកស៊ីការទំនាក់ទំនងជាមួយថៃ នឹងដោយឯកតោភាគីដោយខ្លួនឯងបានទេអារឿងនេះ ដូចថាយើងលក់ផលិតផលអីមួយអញ្ចឹងយើងមានក្រុមហ៊ុនគេមកទិញផ្សេង មិនមែនថៃមកទិញទេគឺមានខ្មែរយើងមកទិញទិញយក ទៅលក់ឲ្យថៃជារឿងរបស់គេ ដល់យើងចេះតែទាក់ទងខ្មែរគ្នាយើងឲ្យមកទិញទៅដូចជា ពោត តាឡូង សណ្តែកអញ្ចឹងទៅណាស់ ។

ដានី ៈ ខុសពីមុន? កាលពីមុនដូចថាមិនទាន់សមាហរណកម្មដំបូងចេញចូលថៃ រកស៊ីអីខុសពីឥឡូវយ៉ាងម៉េចដែរ?

សុត ៖ ខុសពីមុន ព្រោះពីដើមកាលមិនទាន់មានផ្សារ មានដូរអីទាក់ទងគ្នាជាមួយរាជរដ្ឋាភិបាល យើងទៅទិញតែថៃទេ ថៃមិនដែលថាអីទេ ហើយយើងទៅទិញជាមួយគេវាល់ៗល្ងាច ទើបមកវិញខោអាវស្បៀកពាក់អីយើងទិញពីគេហ្នឹង ហើយលក់ដូរអីថាបើឥឡូវយើងដាំ ពោតបានយើងទៅទាក់ទងថៃលក់បានពីដើម តែដល់យើងបង្កើតរដ្ឋាភិបាលមៅមានភូមិ ឃុំទៅយើងអត់ហានទេ គេមានច្បាប់ទំលាប់ទៅ ។

ដានី ៖ ចុះបើយើងចេញចូលទៅទិញគុយទាវហូបបានទេ?

សុត ៖ ទៅបានតែដឹយើងមានសំបុត្រយើងត្រឹមត្រូវ ។

ដានី ៖ ចុះបើយើងអត់មានសំបុត្រ?

សុត ៖ អត់មានសំបុត្រទៅមិនបាន ។

ដានី ៖ ចុះបើកាលពីមុន?

សុត ៖ អត់អីទេ!មិនចាំសំបុត្រ កាលហ្នឹងវាមិនទាន់មានច្បាប់មានទំលាប់ ។

ដានី ៖ កាលពីមុនសមាហរណកម្មយើងឆ្លៀតដាំបន្លែបន្កា ដាំដំនាំអី ដូចធ្យូងអីយើងលក់ឲ្យគេ គេចូលមកទិញអី?

សុត ៖ បាទ!អត់ទេអាហ្នឹងដូចថាឥឡូវយើងទាក់ទងទៅគេអារឿងលក់ធ្យូងអញ្ចឹងទៅ គេឲ្យយើងយកទៅឲ្យគេ ឲ្យយើងលួចឆ្លងអូរទៅ គេមកយកពីយើង ដូច្នេះយើងទាក់ទង ថៅកែណាមួយដែល យើងស្គាល់ទៅ ទាក់ទងអីផ្សេងៗទៀតយើងគិតតាមហ្នឹង គេម៉ោយកអញ្ចឹងយើងស្រួលដែរ អត់មានអ្នកណាលួចអ្នកណា ។

ដានី ៖ ចុះដល់ពេលឥឡូវ?

សុត ៖ ឥឡូវតាមឈ្មួញកណ្តាល គេអ្នកយកទៅលក់ឲ្យ គេមិនប្រាប់យើងថាតំលៃលក់បាន ប៉ុន្មានៗគេមិនប្រាប់យើងផង ។

ដានី ៖ ចុះពូឆ្នាំណាទៅបានពូទៅលេងស្រុកទៅ?

សុត ៖ ខ្ញុំបានទៅលេងស្រុកពេញលេញគឺឆ្នាំ៩៦-៩៧ហ្នឹងឯង កាលឆ្នាំ៩៣ខ្ញុំទៅម្តងដែរទៅលេងម្តាយអីហ្នឹង កាលទៅហ្នឹងខ្ញុំទៅលួចលាក់ទេអត់មានប្រាប់គេទេ ។

ដានី ៖ ប្រាប់អ្នកខាងក្នុងឬខាងអ្នកខាងក្រៅ?

សុត ៖ ខាងក្នុងហ្នឹងណាស់ ។

ដានី ៖ ទៅបានប៉ុន្មានដង?

សុត ៖ ដល់៩៨-៩៩ខ្ញុំបានទៅទៀតទៅជិតបានមួយឆ្នាំ ។

ដានី ៖ អ៊ូ! ស្រុកភូមិជិតដែរ?

សុត ៖ ជិតដែរ នៅបាត់ដំបងនេះ ។

ដានី ៖ ហើយកាលពីមុនពូទៅលេង ដូចថាចេញពីផ្ទះតាំងពីឆ្នាំ៧៨ដល់ពេលឆ្នាំ៩៣ យើងទៅលេងផ្ទះបានមួយដង?

សុត ៖ បាទ! បានមួយដង ។

ដានី ៖ ចុះកាលហ្នឹងមានដឹងដំណឹង មានទាក់ទងគ្នាថាពូនៅរស់នៅហ្នឹងដែរឬអត់?

សុត ៖ បាទ!ដឹងបងគាត់ម៉ោ គាត់ធ្លាប់ម៉ោដែរ កាល៩០-៩១គាត់លួចម៉ោ ។

ដានី ៖ គាត់លួចម៉ោដែរ?

សុត ៖ គាត់លួចម៉ោតាមច្រកស្ងាត់ៗ ដល់ហ្នឹងទាហានយើងគេស្គាល់យើងទៅគេជូនយើងមកដល់កន្លែងយើងនេះ ។

ដានី ៖ ហើយគាត់ទៅវិញឬគាត់នៅហ្នឹង?

សុត ៖ ទៅវិញយើងឲ្យចេញទៅតាមផ្លូវប៉ៃប៉ែតទៅ នៅកន្លែងអ៊ុំ ម៉ុងយើង ។

ដានី ៖ អ៊ុំ ម៉ុង ម៉េចទៅ?

សុត ៖ អាកន្លែងម៉ុងចិន ។

ដានី ៖ អញ្ចឹងគាត់ម៉ោទាក់ទងគ្នាដែរ? ដឹងថាពូរស់នៅតំបន់ហ្នឹង?

សុត ៖ ដឹង គាត់ទាក់ទងយើង យើងឲ្យដំណឹងទៅ នៅឆ្នាំ៩០-៩១-៩២ហ្នឹងឯង ។

ដានី ៖ ដល់ពេលៗ?

សុត ៖ ដល់ឆ្នាំ៩៣បានទៅលេងម្តងអញ្ចឹងទៅ ។

ដានី ៖ កាលហ្នឹងទៅលេងបានយូរទេ?

សុត ៖ ទៅមាអាទិត្យអីហ្នឹង ។

ដានី ៖ បានជួបបងប្អូនសាច់ញាតិ?

សុត ៖ បានជួបមិនសព្វទាំងអស់ទេ គ្រាន់តែជួបមួយផ្នែកណាមួយ ។

ដានី ៖ តើមានអារម្មណ៍យ៉ាងណា?

សុត ៖ ទេមិនអីទេគ្រាន់តែយើងចង់សួរដីធ្លីយើងអីអស់ហើយ គេចែកអស់ហើយយើងមិនបាន វិញទេ គេកែ គេហៅថាការកែប្រែរបបពីសង្គមមួយទៅសង្គមមួយ យើងគិតឃើញដែរ ថាបើយើងទៅវិញក៏គ្មានដីដែរ ។

ដានី ៖ ពូកាលហ្នឹងពូចង់ត្រឡប់ទៅនៅស្រុកវិញដែរ?

សុត ៖ យើងទៅដំបូងនៅឆ្នាំ៩៣ យើងគិតចង់ទៅនៅវិញដែរ តែទទួលខ្ញុំគេធ្វើសមាហរណកម្មចែកដីធ្លីអស់ដែលប្រជាជនគេនៅហ្នឹងអស់ហើយ យើងមិនអាចទៅនៅវិញបានទេ យើងទៅស៊ើបមើលដើម្បីចង់ទៅនៅ ក៏ប៉ុន្តែបើសិនជាមានគេនៅយើងមិនបាច់ទៅទេ ។

ដានី ៖ ចុះបើនិយាយពីអារម្មណ៍ ពីមនោសញ្ចេតនាស្និតស្នាលវិញ ដូចពូធ្លាប់កាលពីមុនចេញពីផ្ទះកាលពីក្មេងៗពូធ្លាប់នៅជាមួយឪពុកម្ដាយនៅឯភូមិកំណើតដូចថាមានបងប្អូន មានសាច់ ញាតិមានមិត្តភក្រ្តមានក្រុមគ្រួសារអញ្ចឹង ដល់ពូបែកចេញម៉ោមកនៅនេះតាំងពីឆ្នាំ៧៩ ពូមកនៅនេះពូមានមិត្តភក្រ្ត សាច់ញាតិថ្មីទៀតផ្សេងទៀត អញ្ចឹងមនោសញ្ចេតនាវាងពូខុសពីមុនយ៉ាងម៉េច?

សុត ៖ ដូចក្មួយឯងដឹងហើយថាពូមកនេះវាយូរ តាំងពី៧៨រហូតមកដល់ឥឡូវវាមិនធម្មតាទេណា៎វាឡើង៣០ជាងទៅហើយ ដូច្នេះអាការបែកគ្នា ស្គាល់គ្នាតិចណាស់ ស្គាល់តែជំនាន់គ្នាហ្នឹងអាជំនាន់តមកទៀតគឺលែងស្គាល់គ្នាហើយ ដូច្នេះការទំនាក់ទំនងបងប្អូនអត់ដូចមុនទេ យើងមើល ទៅគេក៏អត់ដូចមុនដែរ ព្រោះយើងនៅដែលគេឃើញរយៈពេលខ្លីពេក ដូច្នេះអាក្រោយៗគេអត់ស្គាល់យើងទេ អាជំនាន់មុនកើតស្រករគ្នាគេស្គាល់ដែរ គេស្គាល់ទាំងស្រពិចស្រពិលទៀត ។

ដានី ៖ គេមិនបានស្គាល់យើង?

សុត ៖ គេមិនសូវស្គាល់យើងយូរ ការទំនាក់ទនងវាពិតមែនតែបងប្អូនមែន ក៏ប៉ុន្តែមិនដូចពីដើមទេហើយក៏មិនអាចទុកចិត្តគ្នាដូចពីដើមដែរ តែបើនិយាយពីការរស់នៅនេះ អ្នកជទៃដូចខ្សែង សាំងអញ្ចឹង ស្រលាញ់រហូតមកដល់ឥឡូវគឺមិនអាចមានបញ្ហានឹងគ្នាទេ គឺការរស់នៅ ជាមួយគ្នារយៈពេលយូររាប់សិបឆ្នាំទៅដូច្នេះវាមិនដែលមានបញ្ហានឹងគ្នា មិនដែលទាស់គ្នា មិនដែលវាយតបគ្នាមិនដែលឈ្លោះគ្នា ដ៏ឈ្លោះគ្នាឥឡូវនេះគឺឈ្លោះគ្នាអត់រួចទៀត បើអ្នកឯងនិយាយខ្លាំងយើងអត់និយាយ ដល់ពេលឈប់និយាយទៅ និយាយរកគ្នា វិញដដែល សើចដាក់គ្នាវិញដដែលលើកលេងតែបងប្អូនបង្កើតទើបយើងស្និតស្នាលគ្នា បើទឹមបងប្អូនជីដូនមួយមិនស្និតស្នាលគ្នាទេអត់ដូចពីមុនទេ ។

ដានី ៖ ចុះបងប្អូនពូបង្កើតៗនៅហ្នឹងទាំងអស់ អត់មានមកនៅនេះទេ?

សុត ៖ មកនៅនេះពីរនាក់ ។

ដានី ៖ មកនៅឆ្នាំណា?

សុត ៖ ប្អូនខ្ញុំអាពៅមកនៅឆ្នាំ៨៦ ។

ដានី ៖ មកតាំងពីឆ្នាំ៨៦?

សុត ៖ ៨៦មកនៅខាង៣២០ មកនៅដឹកជញ្ជូននៅខាងហ្នឹងម៉ង ឥឡូវវានៅហ្នឹងដដែល ។

ដានី ៖ ហើយមួយទៀត?

សុត ៖ មួយទៀតទៅនៅស្រុកថ្មគោល ។

ដានី ៖ អញ្ចឹងពូទៅលេងស្រុករាល់ឆ្នាំដែរ?

សុត ៖ បាទ!រាល់ឆ្នាំ ទេទើបតែឆ្នាំហ្នឹងទេអត់បានទៅ ។

ដានី ៖ ទៅៗលេងឬយើងទៅធ្វើបុណ្យ?

សុត ៖ ទៅលេងអញ្ចឹងទៅ ឬទៅធ្វើបុណ្យសង្ឃកទានអីមួយ ឲ្យតែទៅគឺធ្វើបុណ្យសង្ឃកទានបន្តិចបន្តួចហើយ ។

ដានី ៖ ហើយទៅរយៈពេលប៉ុន្មានដែរ?

សុត ៖ ទៅយូរដែលហ្នឹងម៉ាអាទិត្យ ។

ដានី ៖ ទៅទាំងពីរនាក់ មីងគាត់ទៅជាមួយដែរ?

សុត ៖ ទៅទាំងពីរនាក់ ជួនកាលកូនវាទៅជាមួយដែរ ។

ដានី ៖ កូនគាត់ស្គាល់ស្រុកកំណើតពូដែរ?

សុត ៖ ស្គាល់ខ្ញុំនាំទៅស្គាល់អស់ហើយ ។

ដានី ៖ មីងអ្នកស្រុកកំណើតនៅណា?

សុត ៖ អ្នកស្រុកកំពង់ចាម ។

ដានី ៖ កំពង់ចាមនៅណា?

សុត ៖ នៅតំបែរ ។

ដានី ៖ ពូធ្លាប់ទៅដែរ?

សុត ៖ បាទ!ទៅហ្នឹងញឹកដាងនេះផង ។

ដានី ៖ អ្ហូ!ទៅញឹកដាងទៀត?

សុត ៖ ព្រោះម៉ែទើបស្លាប់ឆ្នាំទៅ ម៉ែក្មេកខ្ញុំ មួយឆ្នាំខ្ញុំទៅម្តង ទៅហ្នឹងហើយ ម៉ោនេះៗ ។

ដានី ៖ ចុះពូដូចថាកាលពេលពីកងចល័តម៉ោរហូតដល់មៅ៧៦ពូមានធ្លាប់ឲ្យបាយឲ្យទឹក ឬឲ្យអង្ករទៅអ្នកណាដែល ពូធ្លាប់ជួយសង្គ្រោះអីពីណាដែលឬអត់?

សុត ៖ មានពេលមួយខ្ញុំឃើញនារីដឹកជញ្ជូនមានគ្នា៣-៤នាក់ ដើរទៅស្គមៗអត់មានបាយទឹក អង្ករអញ្ចឹងណាស់ ឃើញអញ្ចឹងយើងឲ្យអង្ករឲ្យអីគ្នាហូបទៅព្រោះគ្នាវាអត់ អាហ្នឹង ចំពោះផ្នែកកង

ដឹងជញ្ជូនហ្នឹងពេលយើងជួបយើងឲ្យទៅ តែចំពោះប្រជាជនយើងមិនដែល ជួបទេ ព្រោះប្រជាជនគាត់នៅផ្សេងនៅព្រំដែនគាត់មានរបបផ្សេង ប៉ុននេះអត់ទេ៧៩ ពិតមែនគ្រាន់តែនៅព្រំដែន គាត់ទាក់ទងជាមួយថៃគាត់មានរបស់ដោះដូរ យើងមិន ដែលដឹងពីទុកគាត់ទេ ។

ដានី ៖ ពេលរត់ ធ្វើដំណើរ?

សុត ៖ ធ្វើដំណើរហ្នឹងយើងអត់ដែលដឹងថាគាត់យ៉ាងម៉េចទេ ព្រោះយើងនៅតាមជួរ ។

ដានី ៖ ចុះពេលកាលជំនាន់៣ឆ្នាំ កាលនៅកងចល័តពូមានដែលធ្លាប់ឲ្យអី?

សុត ៖ កាលនៅ៣ឆ្នាំយើងសុំតែក្បាលសុខខ្លួនយើង ដម៉ោនៅកន្លែងយើងៗចេះតែលួចឲ្យបន្តិចៗទៅ ។

ដានី ៖ ចុះសព្វពូមានធ្លាប់លឺពីតុលាការគេបង្កើតកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

សុត ៖ លឺៗ រឿង០០១ ០០២នោះណា ។

ដានី ៖ ពូតាមដានរឿងនេះដែរ?

សុត ៖ ខ្ញុំតាមដានដែរហ្នឹង ។

ដានី ៖ ពូយល់ឃើញម៉េចដែរតុលាការនេះបើតាមចិត្តពូផ្ទាល់?

សុត ៖ អានេះចំពោះខ្ញុំវិញគឺថាមានការកាត់ទោសនេះគឺជារឿងប្រវត្តិសាស្ត្រ ធម្មតារឿងប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗតែងតែមានការកាត់ទោសវាមិនខុសទេ វាជារឿងរបស់អ្នក ឯងអ្នកឯងត្រូវទទួលខុសត្រូវ ហើយខ្ញុំក៏មិនដែលស្គាល់អ្នកទាំងអស់នោះទេ ។

ដានី ៖ អត់ដែលស្គាល់តា អៀង សារីទេ?

សុត ៖ អត់ទេ!អត់ដែលស្គាល់មុខគាត់ទេ អត់ដែលមានទំនាក់ទំនង គេស្គាល់តែពួកកងពល ប្រហែលជាគេមិនឲ្យយើងស្គាល់មុខទេ ។

ដានី ៖ បាទ!ខ្ញុំដូចជាអស់សំនួរអីសួរពូទៀតហើយ ពូមានអីចង់បន្ថែមទេ?

សុត ៖ ខ្ញុំដូចជាអត់មានអី ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណពូច្រើន ដែលចំណាយពេលឲ្យខ្ញុំសួរទាក់ទងពីរឿងជីវិតរបស់ពូ ខ្ញុំអរ គុណពូច្រើន ។

«ចប់»